សៀវភៅគតិលោក

ភាគទី៦



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

CHANBOKEO.COM
ឆែន បន្ទុះអាន

រឿងសត្វកង្កែបនិងគោ

មានសត្វកង្កែប១ នៅក្នុងស្រះថ្ងៃមួយមានគោ១ ចុះទៅផឹកទឹកស្រះនោះ កង្កែបឃើញហើយក៏នឹកក្នុងចិត្តថា អាសត្វគោនេះម្តេចរូបវាធំម្ល៉ះ បើដូច្នេះអញនឹងបំពើតកាយបំប៉ោងខ្លួនឲ្យធំដូចគោនេះបានអេះ កង្កែបគិតដូច្នោះហើយតាំងបំប៉ោងកាយ ចំអើតជើងទ្បើង ហើយហៅទៅកាន់គោនោះថា "នែប្រសែ្តងគោចូលមើលមករូបយើងឯងណេះយើងធំប៉ុនប្រសែ្តងឯងហើយឬ?។

ឯគោក៏តបថា "នៅទេចៅកង្កែបចូរខំបំពើតបំប៉ោងទ្បើងបន្តិចទៀត"។ កង្កែបឮដូច្នោះ ក៏ខំប្រឹងកាងចំកោងបំពើតប៉ោងទ្បើងលើសមុន ហើយក៏ហៅទៅគោថា "ម៉ែចម្តងណេះ ប្រសែ្តងគោរូបយើងធំប៉ុនអ្នកឯងហើយឬៗនៅទាស់ត្រង់ណាទៀត?។

ឯគោក៏តបថា "នៅទេកង្កែបចូរខំប្រឹងបំប៉ោងទ្បើយទៀតទៅ"។ កង្កែបក៏ខំប្រឹងទាំមាត់តាំងកាងចំកោងបំប៉ោងពេញកំលាំង ខ្យល់អស្សាសបស្សាសដង្ហើមចូលចេញមិនបាន កាយកង្កែបនោះក៏បែកធ្លាយ ចេញពោះទៀនលៀនលេចមក

ខាងក្រៅដល់ន្ទូទៅមរណកាលក្នុងកាលនោះហោង។

រឿងនេះ បានគតិអ្នកតូចចង់ជាធំគឺចង់ត្រាប់កាយអ្នកធំពុំសមក្តីប្រាថ្នា ក៏វិនាសអាត្មាឯងវិញ។ មួយទៀត បានគតិដូចបុរាណតែងថា "ដំរីជ្រុះៗតាមដំរី" នោះឯង មួយទៀតមានបទបាលីក្នុងគម្ពីរលោកនីតិថា៖

អប្បរុចោ ពហុភាសោ
អប្បបញ្ញោ បភាសិតោ
អប្បបុភេ ឃដេ ខោភេ
អប្បឥភ តារិ ចលេ។

ប្រែថា ជាតិអ្នកទាបភាពតូចសំដីខ្ពស់ ឥតប្រាជ្ញាឈប្រកាសថ្លែង ពាងក្អមទឹកមិនពេញក្រឡកគ្រលែង មេគោឯងទឹកដោះតិចតែចធាក់ក្រានៗ

មួយទៀតថា៖

អជនស្ស រសំ ខាជា
អពលស្ស ហតា ឆភ
អប្បញ្ញស្ស ភក្សា កថា
ឧម្មត្តកសមា ឥមេ។

ប្រែថា អ្នកឥតធនធាន ចង់ទទួលទាន រសឆ្ងាញ់លើសលែង អ្នកឥតកម្លាំង ចង់តាំងសំដែង ចំបាប់ទាត់ប៉ែង សំដែងអំនួត ។ អ្នកឥតប្រាជ្ញា ល្មោភថ្លែងចរចា ប្រាថ្នាគេអួត ជនពាលនេះប្រៀបទុកស្មើមនុស្សឆ្កួត ព្រោះទើងអំនួត ល្មោភហួសប្រមាណ ។

ចប់តម្រាតូចចង់ធ្វើធំទី ២៣។

ទើងលាឈ្មោល ១ ត្រាប់តាមកូនឆ្កែ

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វលាឈ្មោល ១ ជាសត្វចិញ្ចឹមជាពាហន:របស់សេដ្ឋី លានោះបានឃើញសេដ្ឋីជានាយស្រឡាញ់ឱបរឹតប្រទែ្បងលែង និងកូនឆ្កែជាប្រក្រតីទើបគិតថា អាកូនឆ្កែនេះវាចេះធ្វើលើសអញ្ជឹ បានជានាយគាត់ស្រឡាញ់ឱបរឹត ស្ទួទ្ស្នាលនឹងវាដល់ម្ល៉ះ បើដូច្នេះអញ្ជឹចាំមើលលោកនាយបើគាត់មកជិតអញ្ជឹកាលណាអញ្ជឹនឹងលោទៅឱបគាត់ ឲ្យគាត់ឱបរឹតអញ្ជឹប្រទែ្បងលែងឲ្យដូចជាអាកូនឆ្កែនោះខ្លះ គិតហើយលាវង់ចាំមើលសេដ្ឋី លុះសេដ្ឋីដើរមកជិតខ្លួនបានឱកាសហើយ ក៏លោដើងទាំងពីរទៅនឹងឱបសេដ្ឋីជានាយ ។

ឯសេដ្ឋីឃើញលាចំប្រាទៅមកដូច្នោះ គិតថាលាលោមកនឹងធាក់

ច្រំអាត្មា ទើបខឹងលាក៏ចាប់ដំបងវាយសំពងលានោះ ៥ ៦ដំបង ហើយដេរខ្មោចអាលាចង្រៃ កាចខ្ញូចអ្វីម្ល៉ះវាហ៊ានគិតនឹងធាក់ច្រំខាំឯងជាម្ដង ឯលានោះត្រូវដំណាំ ៥ ៦ ដំបងដល់នូវទុក្ខវេទនា កើតទោមនស្ស តូចចិត្តអាណិតខ្លួនព្រោះពុំសមក្តីប្រាថ្នាឲ្យដូចជាកូនឆ្កែនោះឯង ។

ទើងនេះ បានគិតដូចបុគ្គលឃើញនាយចៅហ្វាយឬអ្នកធំលោកមានចិត្តស្ទឹត្រលែងលំអកចំអន៊ងនឹងអ្នកឯណាមួយ ហើយខ្លួនឯងលោកមិនដែលលែងលសោះទើង ហើយទៅនិយាយឬប្រើអាការស្ទួទ្ស្នាដូចជាបុគ្គលដែលលោកធ្លាប់លែងនោះប្រព្រឹត្តទៅមិនបានដូចគេទេ តែប្រព្រឹត្តហើយគង់ដល់ក្តីបរាមុខនាកណ្តាលជំនុំប្រជុំជន ដូចយ៉ាងលាចង់ត្រាប់កូចឆ្កែនេះឯង គួរចូលចិត្តហោង ។ មួយទៀត ចុះគិតថា "គេមិនលែង ខ្លួនទៅលែង គេមិនសួរ ខ្លួនទៅថ្លែង" ការអស់នេះ បានក្តីហិនលក្ខណ:ក្នុងលោកយនេះប្រាកដ ដូចបទបាលីក្នុងគម្ពីរលោកនីតិថា:

អនភ្ឃយំ តមយាចេ្ច អបុច្ឆា ពហុភាសកោ
អតក្កុណំ បកាសេច្ចេ តិរីដំ ហិនលក្ខណំ ។

ប្រែថា គេមិនហៅចូលទៅ ទៅមិនគួរ គេមិនសួរឆ្លើយឯង

លើសប្រមាណ ក្រកាសគុណនៃកាយដែលពុំមាន បីនេះបាប ឈ្មោះហៅហីនលំក្ខណ៍ ។

ចប់តម្រោគតិធំត្រាប់តូចខូចខ្លួនទី ២៤។

ទៀងចៅគង្វាលពពែម្នាក់

មានចៅគង្វាលពពែម្នាក់កៀងពពែទៅឲ្យស៊ីស្មៅនៅព្រៃក្រៅ១ នាំសុនខស្រុក១ ទៅផងលុះទៅដល់ដើមឈើធំ១ មានម្ដប់ត្រជាក់សប្បាយ ចៅគង្វាលពពែក៏ដោះអាវដោះមួក ដាក់ពាក់ទៅលើមែកឈើ ដាក់ឈើច្រត់ផ្អែកទៅលើប្រគាបឈើ ១ ហើយដេកលេងរំហើយខ្យល់ ឯឆ្កែស្រុកនោះ ក៏ដេកនៅខាងខ្លួន លុះត្រូវខ្យល់ត្រជាក់ ចៅនោះក៏ដេកលក់ ទាំងឆ្កែក៏ដេកលក់នៅក្រោមដើមឈើនោះឯង ។

កាលនោះមានឆ្កែព្រៃ១ ដើរមក ឃើញហ្វូងពពែច្រើនគឺតចង់ចាប់ស៊ី តែចូលទៅជិតហ្វូងពពែកាលណា ពួកពពែទាំងឡាយភិតភ័យផ្អើល នាំគ្នាបោលចូលទៅកាន់សំណាក់ឆ្កែស្រុក ឯងម្ចាស់ទាអស់ទៅ ឆ្កែព្រៃរកឱកាសនឹងចាប់ពពែនោះពុំបាន ។ ថ្ងៃមួយ ឆ្កែព្រៃគិតថា អាពួកពពែអស់នេះតែទាឃើញរូបអញ្ចឹកាលណា ទាសឹងផ្អើលបោលទៅរកម្ចាស់ទា ឲ្យជួយតែទាល់

ដង ឯត្រង់ម្ចាស់ទាដើរមកជិតម្ដេចក៏ទាមិនផ្អើល បើដូច្នេះចាំអញទៅលួចយកអាវមួកនឹងឈើច្រត់ មកស្លៀកពាក់ត្រាប់ឲ្យដូចម្ចាស់ទាទើបទាមិនផ្អើល ជាឱកាសងាយចាប់ស៊ីបាន ឆ្កែព្រៃគិតដូច្នោះហើយ ទើបដើរអមទាងចូលទៅមើលអាការនាយគង្វាលនោះ លុះឃើញនាយគង្វាលនឹងឆ្កែស្រុកដេកលក់ ក៏ចូលទៅលួចយកអាវនឹងមួកមកពាក់ ហើយកាន់ឈើច្រត់ក្រោកដើរដើងពីរអាការដូចជាមនុស្ស ចូលទៅក្នុងហ្វូងពពែបាន ។

ឯពពែទាំងឡាយ ឃើញអាវមួកនឹងឈើច្រត់ដូច្នោះ ក៏នឹកសំគាល់ថាជាម្ចាស់នៃខ្លួន ទើបពុំភិតភ័យភ្ញាក់ផ្អើលដូចកាលមុន ។ នាំគ្នារកស៊ីស្មៅនូវស្លឹកឈើទៀងខ្លួនទៅ ។

ឆ្កែព្រៃតាំងកៀងហ្វូងពពែនោះ ឲ្យចូលទៅក្នុងព្រៃធំគឺតថាម្ចាស់ទានោះ កាលនឹងកៀង នឹងដេញតែងបញ្ជោញ្ជសពុំថាហ៊ីរ៉ៃយ ។ យ៉ាងនេះ បើដូច្នោះគួរអញ្ចឹបញ្ជោញ្ជសពុត្រាប់ឲ្យដូចម្ចាស់ទា គឺតហើយក៏ស្រែកដេញថាហ៊ីរ៉ៃយ ។ ដូច្នេះឯសម្ដែងឆ្កែព្រៃដែលស្រែកនោះ មិនដូចសម្ដែងមនុស្ស ព្រោះជាជាតិខុសគ្នា សត្វតិរច្ឆានត្រាប់សម្ដែងមនុស្សមិនដូច តែស្រែកទៀងក៏ចេញប្រចក្រជាសព្ទឆ្កែព្រៃធម្មតា ទើបពពែទាំង

ឡាយកើតភិតភ័យផ្អើលបោល ស្រែកកងរំពងជាកោលាហល
ទៀងៗ ឯនាយគង្វាលពពែនឹងឆ្កែស្រុក បានឮសព្ទពពែផ្អើល
ស្រែកយំកង ក៏ភ្ញាក់ចាកនិទ្រាក្រោកម្ចឹងម្ចាទៅកាន់ហ្វូងពពែបាន
យល់ឆ្កែព្រៃលួចយកអាវិមួក នឹងឈើច្រត់របស់ខ្លួនទៅប្រដាប់
ខ្លួនវាធ្វើអាការដាមនុស្សដូច្នោះ នាយគង្វាលពពែក៏បង្ហៅឆ្កែ
ស្លូតឲ្យដេញខាំឆ្កែព្រៃ ហើយជួយគ្នាវាយឆ្កែព្រៃនោះ ដួល
ចុះដល់នូវកំពូលកណ្តាលព្រៃធំនោះហោង នាយគង្វាល
ពពែក៏ដោះយកអាវនឹងមួក អំពីសាកសពនៃឆ្កែព្រៃនោះមក
វិញហើយក៏ដេញពពែវិលមកផ្ទះនៃអាត្មាហោ ។

ទៀងនេះ បានគតិដូចមនុស្សចង់សំដែងកាយឲ្យដូចគេអ្នក
ជាតិខ្ពស់ ទោះជាធ្វើយ៉ាងណាៗ ក៏គង់មិនដូចគេគង់ចេញកិរិយា
ប្រក្រតីខ្លួននោះមកខាងក្រៅឲ្យគេស្គាល់ជាតិខ្លួនបាន ដូចយ៉ាង
ឆ្កែព្រៃលួចយកអាវិយកមួកគេពាក ទាំងកាន់ឈើច្រត់ជាដំបង
អាការខាងក្រៅនោះ ធ្វើទៅបានដូចមនុស្សប្រាកដ តែសព្ទ
សម្តែងខាងក្នុង ធ្វើទៅពុំដូចមនុស្ស ពួកពពែអាចស្គាល់ជាឆ្កែ
ព្រៃទៅបាន ។ បទនេះសមដូចពាក្យគតិបុរាណថា "សម្តែង
ប្រាប់ភាសា កិរិយាប្រាប់ត្រកូល" ដូចជាតិអ្នកបាសាក់ព្រះត្រ

ពាំង អ្នកសៀមរាប ឬអ្នកប្រទះឡាងជាដើម មនុស្សពួកអស់
នេះ ទោះស្លៀកពាក់តែងរូបកាយប្រដាប់ ដូចអ្នកក្រុងយ៉ាង
ណាត្រាប់បាន តែបើហានិយាយទៀងកាយណាសម្តែងនោះ
ប្រាប់ឲ្យគេដឹងថា ខ្លួនជាអ្នកបាសាក់ព្រះត្រពាំង សៀមរាប
ស្រុកប្រទះឡាង មានអាងនឹងសំនៀងប្រាប់ភាសាខ្លួនស្រាប់ ។

មួយទៀត លោកអ្នកផ្សេងភាសាគ្នា ទោះចេះនិយាយបាន
យ៉ាងណាៗ សំនៀងបែងនោះចេញឲ្យគេដឹងថាអ្នកនេះជាចិន
ឆៅ អ្នកនេះជាយួន ជាសៀមជាដើមទៅបាន ។ បទអស់នេះ
អ្នកប្រាជ្ញគួរពិចារណាទៅទៀតចុះ ។

ចប់តម្រាគតិអ្នកទាបត្រាប់ភាសាអ្នកខ្ពស់ទី ២៥។

ទៀងចៅមាណពម្នាក់ចិញ្ចឹមមេឆ្នា ១

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានចៅមាណពម្នាក់ចិញ្ចឹមមេឆ្នា ១ ទុកសម្រាប់ឲ្យខាំកណ្តុរ
មេឆ្នានោះមានមារយាទល្អ ចៅមាណពក៏ស្រឡាញ់មេឆ្នានោះ
មហិមា តែពេលចូលនិទ្រាកាលណា ក៏ហៅមេឆ្នានោះមកដេក
ជាមួយនឹងខ្លួនតែសព្វៗថ្ងៃ មេឆ្នាក៏មានចិត្តស្រឡាញ់ម្ចាស់
ដោយភាពសត្វ ចៅមាណពស្រឡាញ់ឆ្នាខ្លាំង ក៏តាំងអធិដ្ឋាន

សំពះបន់ស្រន់ដល់ព្រះឥសូរថា "ព្រះម្ចាស់ទេវតាអើយសូមមកជួយប្រសិទ្ធិរូបមេឃ្មានេះ ឲ្យក្លាយកាយតើតជាស្រីមនុស្សទៀង ខ្ញុំនឹងយកជាភរិយា"។

គ្រាកាលនោះ ព្រះឥសូរទេវរាជឮចៅមាណពបានឮនឹកដល់គុណខ្លួនក៏អាណិតចៅមាណពនោះទើបហោះមកប្រសិទ្ធិមេឃ្មានោះឲ្យតើតកាយក្លាយជាស្រីក្រមុំ ហើយផ្សំផ្គុំឲ្យជាភរិយានៃចៅមាណពនោះឯង។

ឯចៅមាណពនោះ កាលសមក្តីប្រាថ្នាហើយក៏មានចិត្តត្រេកអរសាទរក្រៃពេកណាស់ ចាប់ដើមពីថ្ងៃនោះ អ្នកទាំងពីរក៏បាននៅរួមសុខទុក្ខជាប្តីប្រពន្ធនឹងគ្នា រកស៊ីចិញ្ចឹមជីវិតដោយភាវៈជាអ្នកស្រែចំការតាមធម្មតាលោកិយ។

ថ្ងៃមួយជាពេលរាត្រី ប្តីប្រពន្ធក៏ចូលនិទ្រាលើគ្រែជាមួយគ្នា កាលនោះមានកណ្តុរ២ គូវាវាទមកខាងនាងភរិយានោះ នាងនោះដោយជាតិជាឆ្នាតែងធ្លាប់ចាប់កណ្តុរ លុះកណ្តុរវាវាទមកខាងខ្លួន ក៏សុះក្រោកលោលោតទៅចាប់កណ្តុរដោយរហ័ស ធ្លាក់ចុះអំពីគ្រែ បោកក្បាលទៅលើដីងគ្រែ។ ឯចៅក្តីក៏ភ្ញាក់ក្រោកម្ចឹងម្ចាំ សុះប្រញាប់ចាប់បានដើងនាងប្រពន្ធហើយលើក

ទៀងតាំងបបក់ព្រលឹងលួង លោមសួរថា "ហៃមាសពីសីមានហេតុអ្វីបានជាប្លុនក្រោកលោតចេញអំពីទំដំណេកដូច្នេះ"។

ឯនាងនោះដឹងខ្លួនក៏តើតក្តីអៀនខ្មាសប្តីបំទេសចក្តីនោះមិនសំដែងឲ្យប្តីដឹងទៀយ ឆ្លើយបង្វែងថាខ្លួនយល់សប្តមមើទៅផ្ទាស ពុំដឹងខ្លួនប្រាណសោះទៀយ។ ឯភរិយានាងឆ្នាប្រព្រឹត្តក្រោកចាប់កណ្តុរនោះមិនមែនតែ១ ទៅលានោះទេតែដែកលក់ហើយមានកណ្តុរវាខាងខ្លួនកាលណា តែងសុះក្រោកលោតចាប់កណ្តុរក្នុងកាលនេះឯង នាងឆ្នាប្រព្រឹត្តយ៉ាងនោះតែទៀងៗមក ទាល់តែចៅប្តីមិនហ៊ានឲ្យដេកលើគ្រែ នាំឲ្យដេកតែនោទីផ្ទៃរាបដរាបអស់អាយុនឹងគ្នា ត្រាតែទៅតាមយថាកម្មហោង។

ទៀងនេះ បានតតីជាតិលះវាស្នាខ្លួនចោលពុំបានតឹខ្លួនធ្លាប់សន្សំនូវអារម្មណ៍ពីដើមយ៉ាងណាមកអារម្មណ៍នោះជាប់តាមមិនដាច់ លះបង់ទៅពុំបានដូចធ្លាប់លេងល្បែងនានា មានល្បែងលេងចំបាប់ប្រដាល់ជាដើម ទោះដល់ខ្លួនចាស់ដរាហើយលើកលែងល្បែងនោះចេញក្តី បើមានអ្នកឯណាមួយទៅនិយាយត្រូវត្រង់អារម្មណ៍ខ្លួនធ្លាប់ប្រព្រឹត្តមកនោះ ក៏តើតចិត្តលោភ

ទៀងសំដែងនូវកិរិយាល្បែងនោះអួតបង្ហាញឲ្យគេបានដឹងបានឮទៀងជាប្រាកដ។

មួយទៀត បុគ្គលកើតក្នុងទឹងត្រកូលដែលមានកិរិយាយ៉ាងណា កិរិយានោះជាប់តាមសន្តានចិត្ត នឹងគិតលះបង់ចោលបានដោយក្រ កិរិយាមារយាទជាកំណើតកើតមកសម្រាប់រូបកាយនេះ សឹងប្រព្រឹត្តទៅជាធ្លូវៃ ជាគន្លងចេញឲ្យគេយល់គេស្គាល់បានក្នុងកាលប្រជុំជន។ បទនេះសមដោយពាក្យបុរាណថា "ត្រកូលសជាតិ មារយាទសព្ងជ" អធិប្បាយថា ជាតិកំណើតល្អអាក្រក់ សឹងប្រព្រឹត្តទៅតាមត្រកូលមែនត្រកូលអ្នកល្អក៏កើតជាតិល្អ មិនលះបង់ជាតិល្អជាតិបណ្ឌិតទៅបាន ទោះធ្លាយធ្លាក់ចុះជាអ្នកក្រីក្រក្តី ក៏លះបង់មារយាទល្អទៅពុំបាន នៅមានមារយាទល្អដដែល។

បទនេះ បានដូចបទបាលីក្នុងគម្ពីរលោកនីតិថាៈ

សុក្ខោបិ ចន្ទនវ្ឫ ន ជហាតិ គន្ធំ
ជាតោ កតោណមុខេ ន ជហាតិ លិដ្ឋំ
យត្ថេ កតោ មជ្ឈិមំ ន ជហាតិ ឧធច្ឆ
ទុក្ខោបិ បណ្ឌិតជនោ ន ជហាតិ ធម្មំ។

ប្រែថា ជាតិខ្លឹមចន្ទន៍ទោះក្រៀមស្វិតក្រញ៉ង់មិនលះបង់ក្លិនក្តែបសុគន្ធា ដំរីសារទោះចូលសឹកយុទ្ធនា មិនលះបង់លីលាស្តាយលុងក្រាយ។ ជាតិអំពៅទោះនៅក្នុងយន្តគាប មិនលះបង់សភាពរសផ្អែមសាយ ជាតិបណ្ឌិតទោះមានទុក្ខក្នុងកាយ មិនដឹងណាយលះបង់ព្រះធម៌ថ្លៃ។

ចប់តម្រាគតិបង់វាស្នាពុំរួចទី ២៦។

ទៀងចៅមាណពម្នាក់ចិញ្ចឹមសុនខត្បៀ ១

មានចៅមាណពម្នាក់ចិញ្ចឹមសុនខត្បៀ ១ ជាទីប្រើប្រាស់ក្នុងការនាំយកវត្ថុអ្វីៗទៅបាន ថ្ងៃមួយចៅមាណពទៅព្រៃដើម្បីកាប់ឈើទ្រនឹព្រៃ ធ្វើចំការពោតបានផ្តាំភរិយាថា ខ្លួនទៅចំការមុន ចាំដល់ពេលថ្ងៃបន្តិចឲ្យយកកញ្ចប់បាយចងកន្ត្រែ ឲ្យនាំយកទៅឲ្យខ្លួនជាក្រោយ ផ្តាំស្រេចហើយចៅនោះក៏ទៅចំការឯព្រៃធ្វើការតាមភាពខ្លួន។

ឯនាងភរិយា លុះដល់ពេលក៏ចំអិនអាហារបានហើយទើបទៀបចាត់ចែងទៅជាបង្ហើចហើយ ចងនឹងកន្ត្រែត្បៀប្រាប់ថា ចូរអានាំអាហារនេះ ទៅឲ្យម្ចាស់អាឯចំការឯណោះឲ្យឆាប់ឯកន្ត្រែនោះក៏ទទួលពាក្យហើយ បោលតម្រង់ទៅឯចំការលុះទៅ

ដល់អ្នកមានទឹកខ្ពស់នៅទឹកនោះជ្រៅ សុនខនឹងលុយឆ្លងទៅពុំ
រួចរកទីទួលគោក ទីទឹកវាក់ឬទូកក្តារឆ្លងពុំបាន ពេលសោតក៏
ជួនថ្ងៃជិតត្រង់ សុនខក៏ប្រថុយលោតហែលឆ្លងទៅដោយកំលាំង
ទហ័ស ឯអាហារក្នុងបង្វែចនោះក៏ទទឹកទាំងអស់ លុះទៅដល់
ម្ចាស់ក៏បោលចូលទៅទៀបជិត។

ឯចៅមាណព ស្រាយយកបង្វែចបាយអំពីកន្លែងយើញបាយ
នោះទទឹកជោកដូច្នោះ ក៏ខឹងនឹងសុនខទើបចាប់ដំបងសំពង
២-៣ ដំបងយ៉ាងដំណាំ ហើយផ្ចាលដោយប្រការផ្សេងៗ ឯសុនខ
នោះលុះត្រូវនាយវាយដូច្នោះ ក៏ឈឺចិត្តអាណិតខ្លួនក្រែពេកទើប
បោលចេញចាកទីនោះ ហើយគិតថាអញនេះជាសុនខកបកម្លាំ
ងខ្លាំងពូកែហើយ ឥឡូវអាដំបងនោះវាពូកែលើសឯងទៅ
ទៀត គឺវាអាចប្រហារកប្បាលឯងបានជាមួង បើដូច្នេះគួរតែ
អញអធិដ្ឋានបន់ទេវតា ឲ្យលោកជួយប្រសិទ្ធិពរអញនេះ
ឲ្យក្លាយទៅជាដំបងវិញ គិតហើយសុនខក៏អធិដ្ឋានថា "ព្រះឥ
សូរជាម្ចាស់អើយ សូមមេត្តាប្រោសធ្វើរូបកាយខ្ញុំ ឲ្យកើតជា
ដំបងហោង"។

កាលនោះ ព្រះឥសូរទេវតាក៏មកប្រសិទ្ធិពរសុនខនោះឲ្យ

កើតជាដំបង សំរេចដូចបំណងនៃឆ្កែតឿនោះឯង ឯដំបង
សុនខចាប់ដើមពីនោះមក ក៏តាំងតែហោះហើរដើរ ទាំយគេ
ទាំយឯងឥតឈប់ឈរគឺទាំយមនុស្សនូវសព្វទូទៅទាំងពិភព។

ឯមនុស្សនឹងសត្វទាំងឡាយ បានក្តីក្តៅក្រហាយទាំងអស់គ្នា
ទើបនាំគ្នាទៀងទៅប្តឹងដល់ព្រះឥសូរាធិបតី តាមដំណើរ
ដែលដំបងសុនខបៀតបៀននោះឯង។ ព្រះឥសូរក៏បណ្តាល
ឥទ្ធិឫទ្ធិនិម្មិតជាភ្លើងឆេះប្រហារដំបងនោះចេញ។ ឯដំបង
សុនខយើញភ្លើងឫទ្ធិមកដុតអាត្មាដូច្នោះ ក៏នឹកថាអញជាដំបង
ថាមានឫទ្ធិខ្លាំងពូកែហើយ ឥឡូវមានភ្លើងខ្លាំងពួកែលើសអញ
ទៀត "ឱ ព្រះជាម្ចាស់ខ្ញុំអើយសូមមេត្តាប្រោសឲ្យខ្ញុំកើតជា
ភ្លើងវិញហោង"។

ព្រះឥសូរាធិបតី ក៏ធ្វើដំបងសុនខនោះឲ្យកើតជាភ្លើង
តាមទំនើងក្តីប្រាថ្នានៃសុនខ ឯភ្លើងសុនខចាប់ដើមតាំងពីកើត
ទៀង ក៏ដើរដុតឆេះព្រៃព្រឹក្សាលតាវល្លិនូវទីភូមិលំនៅទូទៅ
ទាំងពិភព ពុំមានឈប់ឈរទៀង។

ឯមនុស្សនឹងសត្វទាំងឡាយ បានក្តីក្តៅក្រហាយទាំងអស់គ្នា
ទើបនាំគ្នាទៅក្រាបទូលប្តឹងដល់ព្រះឥសូរតាមទៀងនោះឯង។

ព្រះឥសូរក៏បណ្តាលឫទ្ធិឲ្យកើតជាភ្លៀងបង្អុរធ្លាក់ចុះមកលត់ភ្លើងសុនខនោះ។ ភ្លើងសុនខគិតថា ភ្លើងអញនេះអាចហានខ្លាំងពួកែណាស់ហើយ ឥឡូវនេះមានទឹកភ្លៀងវិសេសលើសទីញ្ឈឺ ព្រះម្ចាស់ខ្ញុំអើយ សូមឲ្យខ្ញុំកើតជាភ្លៀងវិញចុះ"។

ព្រះឥសូរក៏បណ្តាលឲ្យភ្លើងសុនខប្រែកើតជាភ្លៀងតាមភ្ជុំប្រាថ្នា ឯភ្លៀងសុនខចាប់ដើមតាំងពីកើតទៀងក៏ចេះតែបង្អុរភ្លៀងធ្លាក់ជន់ជោរលិចព្រៃលិចភូមិស្រែចំការនានា។

មនុស្សនិងសត្វបានក្តៅក្រហាយទឹកទែៗ ទើបនាំគ្នាទៀងប្តឹងដល់ព្រះឥសូរ។

ព្រះឥសូរក៏បណ្តាលឫទ្ធិឲ្យកើតជាខ្យល់បោកផាត់បង្អុតទឹកភ្លៀងឲ្យហែងហួតបាន។ ឯភ្លៀងសុនខឃើញខ្យល់មានអំណាចខ្លាំងដូច្នោះ ក៏អធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាប្រោសឲ្យខ្ញុំកើតជាខ្យល់ទីញ្ឈឺទៅ"។

ព្រះឥសូរ ក៏ធ្វើភ្លៀងឲ្យកើតជាខ្យល់តាមភ្ជុំប្រាថ្នានៃសុនខនោះឯង។ ឯខ្យល់សុនខចាប់ដើមពីកើតទៀងមក ក៏តាំងតែបោកផាត់បំបាក់អស់ឈើព្រៃព្រឹក្សាលតាវល្លិឫទ្ធិទៅសព្វឋានឈើទាំងឫស្សាយធន់ពុំបាននឹងកំលាំងខ្យល់សុនខ សឹងបោកបក់

បោកផាត់បំបាក់អស់ឈើព្រៃព្រឹក្សាលតាវល្លិឫទ្ធិទៅសព្វឋានឈើទាំងឫស្សាយធន់ពុំដួលរលើងរលំទៅផ្សេងៗ នៅសល់តែដំបូកស្ងួយ១ ដុះកណ្តាលវាលពុំកក្រើករំពើកទេ។ ឯខ្យល់សុនខបានឃើញដំបូកស្ងួយនោះ ពុំកក្រើកដោយកំលាំងខ្លួនដូច្នោះ ក៏គិតថាដំបូកនេះខ្លាំងពូកែលើសអាត្មា គួរតែប្រាថ្នាឲ្យកើតជាដំបូកវិញ្ញូប្រសើរវិសេសជាងខ្យល់នេះ គិតហើយសុនខអធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយ មេត្តាប្រោសឲ្យខ្ញុំកើតជាដំបូកវិញ្ញូហោង"។

ឯព្រះឥសូរក៏ប្រសិទ្ធិឲ្យខ្យល់សុនខ ឲ្យកើតជាដំបូកស្ងួយ១ ដុះទៀងនៅកណ្តាលទីវាល។ គ្រានោះ មានមហិង១ ទៅរកស៊ីស្មៅ នៅទីទៀបខាងដំបូក ក្របីនោះវាទមាស់ក្បាលកដល់រឹងដំបូកនោះបែកបាក់ធ្លាក់ចុះ ឯដំបូកសុនខគិតថាអាសត្វមហិងាឯនេះ វាខ្លាំងពូកែលើសដំបូកនេះទៅទៀត បើដូច្នេះគួរអញអធិដ្ឋានឲ្យកើតជាមហិងាវិញ្ញូ គិតហើយអធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាធ្វើឲ្យខ្ញុំកើតជាសត្វមហិងាវិញ្ញូ"។

ឯព្រះឥសូរក៏ធ្វើដំបូកសុនខនោះឲ្យកើតជាសត្វមហិងាតាម

ត្តប្រាថ្នា។ ឯមហិង្សាសុនខចាប់ដើមពីកើតទៀងមក ម្ចាស់និង
ប្រែប្រាស់ពុំសូវបាន ជាក្របីទាញទង់ណាស់ ចងនឹងខ្សែអ្វី។
ពុំជាប់ទៀយ ទើបម្ចាស់នោះយកព្រ័ត្រ ៣ ធ្នង់ទៅចង់កទើប
ជាប់បានមហិង្សាសុនខ ទាញកន្ត្រាក់ព្រ័ត្រនោះពុំដាច់ទៀយ
ហើយគិតថា អាព្រ័ត្រនេះ ទាំពូកែ លើសអញទៅទៀត
"ឱព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាប្រោសឲ្យខ្ញុំកើតជាព្រ័ត្រទៅ
វិញចុះ"។

ព្រះឥសូរក៏ប្រសិទ្ធិឲ្យកើតជាព្រ័ត្រ តាមដោយសេចក្តី
ប្រាថ្នានៃចៅសុនខគ្រាកាលនោះមានឆ្កែតឿ១ចូលទៅឃើញ
ចង្វាយព្រ័ត្រ ក៏កង្កៀមស៊ីដាច់ដាកំណាត់ធំកំណាត់តូច ឯព្រ័ត្រ
សុនខ ឃើញឆ្កែតឿទាំកកេរស៊ីព្រ័ត្រដូច្នោះ ក៏និកថាអាសុនខ
នេះទាខ្លាំងពួកែលើសព្រ័ត្រទៅទៀត "ឱព្រះជាម្ចាស់ខ្ញុំអើយ
សូមមេត្តាប្រោសធ្វើខ្ញុំឲ្យកើតជាឆ្កែតឿវិញចុះ"។

ព្រះឥសូរក៏មកប្រសិទ្ធិព្រ័ត្រនោះឲ្យកើតជាសុនខតឿដូច
ត្តប្រាថ្នា ចៅសុនខក៏បែរហក់ចុះមកជាឆ្កែតឿដូចមុនវិញ
ហោង។

ទៀងនេះ បានគតិដល់បុគ្គលអ្នកប្រាថ្នាចង់តែបានវត្ថុអ្វី។

ពុំដឹងវត្ថុនោះជាសត្រូវធ្លាក់មកត្រូវលើខ្លួនឯងវិញ។

មួយទៀតហៅថា ប្រាថ្នាហួសសំណាង ហួសជាតិហួសកំណើត
ប្រព្រឹត្តទៅមិនផុតឧបនិស្ស័យបទនេះអ្នកប្រាជ្ញគួរគប្បី
ពិចារណាទៅទៀតចុះ។

ចប់តម្រាប្រាថ្នាហួសសំណាងទី ២៧។

ទៀងឆ្កែវង្វែងម្ចាស់និងមហាឥសី

មានសុនខ១ ទៅលេងព្រៃជាមួយនឹងម្ចាស់ទង្វែងបាត់ម្ចាស់
ក្នុងព្រៃអត់បាយ៣ ថ្ងៃពុំបានជួបប្រទះនឹងមនុស្សម្នាក់ទៀយ
ទង្វែងដើរដល់ព្រៃហិមពាន្តបានឃើញអាស្រមសាលា ព្រមហា
ឥសី អ្នកសាងព្រឹទ្ធតាំងនៅទី១ ក៏ចូលទៅនៅអាស្រ័យនឹងមហា
ឥសីនោះ ព្រះមហាឥសីក៏មេត្តាអាណិតឲ្យទានអាហារដែល
សេសសល់អំពីលោក គឺអាហារដែលបានមកពីសាច់ឆ្អែងសត្វជា
សាច់សំណល់អំពីរាជសីហ៍ ខ្លា ឬ សត្វហត្ថីលង្គជាដើមនោះ។

សុនខនោះក៏បាននៅជាសុខសប្បាយ ពុំបានគិតនឹលទៅស្រុក
វិញទៀយ ឯព្រះមហាឥសីថ្ងៃ១ លោកគិតថា សុនខនេះជាជាតិ
សត្វស្រុក អាស្រ័យចិញ្ចឹមជីវិតដោយសារតែមនុស្ស ឥឡូវមក
នៅនឹងអញជាអ្នកនៅព្រៃ អាស្រ័យតែផ្លែឈើមើមឈើជា

អាហារនឹងបានបាយត្រីសាច់ឯណាចិញ្ចឹមទា មួយទៀតជាតិសត្វ
ស្រុកនឹងមកនៅព្រៃឯណោះបាន ព្រោះព្រៃសឹងប្រកបដោយ
ភ័យអន្តរាយ កើតអំពីពាឡម្រឹគមានខ្លារាជសីហ៍ជាដើម បើ
ដូច្នេះ គួរតែអញ្ជើញប្រសិទ្ធិកាយសុនខនេះ ឲ្យក្លាយទៅជារាជសី
ហ៍គ្រាន់គ្នាបាននៅអាស្រ័យជាមួយ នឹងហ្វូងសីហៈផងទាំងឡាយ
គិតហើយព្រះមហាឥសី ហៅឆ្កែនោះមកជិតហើយតាំងបទិកម្ម
ព្រះគាថា ប្រសិទ្ធិរូបសុនខឲ្យក្លាយជាកាយសីហៈទៀងបាន១
រំពេច ឯសីហសុនខបានសំទេចក្តីប្រាថ្នាហើយ ក៏ត្រេអរសាទរ
ក្រៃពេកទៅបក្រាបលាព្រះមហាមុនី ចរលីលាបាលចូលព្រៃ
ទៅនៅអាស្រ័យនឹងហ្វូងសីហៈទាំងឡាយក្នុងព្រៃ១ លុះនៅយូរ
មក ចៅសីហសុនខចង់បាននាងរាជសីហ៍ជាកូនក្រមុំចៅកេសរ
រាជសីហ៍ ទើបចូលទៅនិយាយដណ្តឹងតកេសរនាជសីហ៍ជាបិតាថា
"បពិត្រលោកដ៏ចំរើន! ខ្ញុំខ្ញុំបាននេះ មានចិត្តប្រតិព័ទ្ធស្រឡាញ់
កូនក្រមុំលោកជាភរិយា សូមលោកប្រោសមេត្តាដល់ខ្ញុំបាទ
ចុះ"។ ឯកេសរនាជសីហ៍ឮដូច្នោះក៏តបថា "អើចៅៗស្រឡាញ់
កូនយើងៗក៏ឥតបើថាអ្វីព្រោះការលោកិយតែងមានជាធម្មតា
តែថាពួកយើងពុំទាន់ស្គាល់ពូជពង្សនឹងត្រចៅឯងនេះទៀយមិន

ដឹងជាពូជធានចៅឯងតែដូចម្តេច បើដូច្នេះចាំយើងទៅសួរដល់
ព្រះមហាឥសីជាម្ចាស់ឯងសិន"។ ឯចៅសីហសុនខបានឮកេសរ
រាជសីហ៍ ថាចាំទៅសួរពូជពង្សខ្លួននឹងព្រះឥសីដូច្នោះក៏គិតថា
អាត្មាអញ្ជើចេះជាជាតិពូជសុនខពីតឥតទៀតគេថា នឹងទៅសួរដល់
ព្រះមហាឥសី។ សោតលោកជាអ្នកកាន់សីលសាងព្រឹទ្ធ បើតែ
សួរនលោកហើយ កាលណាទៀយលោកនឹងលាក់កែវ៉ែនអញ្ជើនេះ
បាន គង់លោកប្រាប់គេដោយត្រង់ថាអញ្ជើជាជាតិសុនខពិត
កាលបើគេដឹងថាអញ្ជើជាជាតិសុនខហើយម្តេចទៀយគេនឹងឲ្យ
កូនក្រមុំគេនោះ ជាភរិយអញ្ជើបើដូច្នេះ មានតែអញ្ជើទៅខាំ
សម្លាប់មហាឥសីនោះចេញជាការកាត់ផ្តែវមិនឲ្យពួកអស់នេះ
ទៅសួរ ទៅបញ្ជាក់បាន គិតហើយសីហសុនខលាកេសរសីហៈ
ម្ចាស់ម្ចា បោលទៅកាន់សំណាក់ព្រះឥសី ដល់ហើយក៏សំញែញែ
ធ្មេញ បញ្ចេញសព្ទសំដែងអាការ នឹងលោលោតទៅខាំព្រះ
មហាឥសី។ បែរទោយល់អាការកិរិយាសីហសុនខដូច្នោះ ក៏
ជ្រាបហេតុនោះមួយរំពេចទើបគិតថា អាសត្វនេះកោងកាច
ណាស់ទាគិតនឹងមកសម្លាប់ឯងទៀ បើដូច្នេះនឹងទុកទាជារាជសីហ៍
តទៅឯណោបាន គួរប្រសិទ្ធិកាយទាឲ្យក្លាយទៅជាឆ្កែដូចដើម

ទៅញ្ជូតតហើយព្រតាបសតាំងពីធីប្រសិទ្ធកាយសីហៈនោះឲ្យ
ក្លាយទៅជាសុនខដូចកាលមុនហោង។ ឯសីហសុនខនោះ លុះ
ប្រែកាយក្លាយកើតជាឆ្កែទៅញ្ជូដូច្នោះ ក៏កើតក្តីអរ្យាន្ធាសក្តៅ
ចិត្តនឹងស្តិតនៅក្នុងសំណាក់ព្រះតាបសនោះពុំបាន ក៏បោល
ចោលលំនៅរត់ទៅតាមយថាកម្មនៃអាត្មាទៅញ្ជូហោង។

ទៀងនេះ បានតតិងល់បុគ្គលអកតញ្ញូមិនដឹងគុណលោកអ្នក
មានគុណលើខ្លួន បាននូវទុក្ខទៀនាក្តៅក្រហាយចិត្តប្រចក្រក្នុង
លោកនេះ។

មួយទៀត ជាតិអ្នកថោកទាបហើយទោះបីលោកលើកខ្លួន
ទៀងក៏លូតខ្ពស់ទៅពុំបាន សន្តានទាបក៏ទាបនៅដដែលទៅញ្ជូ
ក្នុងបទលោកថា អស្រ័យកំណើតម៉ែឪថោកទាប ដូចមានបទ
បាលីក្នុងគម្ពីរលោកនីតិថា៖

មាតា ហីនស្ស ទុភាសា
បិតា ហីនស្ស ទុក្រិយា
ឧភោ មាតាបិតភេហិ
ជាទុភាសា ច ទុក្រិយា។

ប្រែថា បើមាតាហីនជាតិកើតបុត្រា បុត្រនោះមានវាចាភាសា
ទាប។ បើបិតាហីនជាតិមាត្រទុរភាពបុត្រនោះទាបកិរិយាអា
ក្រក់នៅ បើម៉ែឪហីនជាតិទាំងពីរនាក់ បុត្រនោះអប្បលក្ខណ៍
ទាំងពីរផ្លូវ ទាំងកិរិយាភាសាក៏ហួងសៅ តាមគន្លងម៉ែឪផ្លូវដូច
គ្នាមួយទៀតថា៖

ទុជ្ជនោ ទោសមាជាយ
ទុកម្មមិវ សូកភោ
សុជនោ សុគុណាត្តាហោ
ហំសោវ ទីរមិច្ចតា។

ជនដួកាន់យកតែទោសទុក្ខ ដូចកលជ្រួកស្រុកប៉ងអាចម
ជនល្អកាន់យកគុណខ្ពស់ត្តម ដូចហង្សប៉ងចំចឹកទឹកដោះ។

ចប់តម្រោគតិជនជួអកតញ្ញូទី ២៨។

ទៀងខុកញ្ជ្រោយោមរាជនឹងខុកញ្ជ្រោពលទេព

មាននាហ្នឹង២នាក់ ម្នាក់ជាទីខុកញ្ជ្រោយោមរាជម្នាក់ទៀតជា
ខុកញ្ជ្រោពលទេព ឯខុកញ្ជ្រោពលទេពជាមនុស្សលោភបុណ្យសក្តិ
ចង់បានទីយោមរាជកើតស្អប់ខុកញ្ជ្រោយោមរាជ គិតស្វែងរក
ទោសដាក់នឹងក្រាបទូលទំលាក់ចាកទីយោមរាជ អាត្មាឯងនឹងបាន

ស្តីទីយោមរាជនោះតទៅខុកញ៉ាពលទេពស្វែងរកទោស
លោកយោមរាជនោះជាយូរខែមក ថ្ងៃមួយមានអ្នកទោសម្នាក់
មានទោសធ្ងន់ ក្រុមជំនុំកាត់ទោសដល់ប្រហារជីវិត។ ឯអ្នក
ទោសនោះដឹងថាថ្ងៃព្រឹកស្អែកនេះហើយ គេនឹងនាំអាត្មាទៅ
សម្លាប់ជាប្រាកដក៏តាំងសៅសោកទិយោគ ស្តាយជីវិតមហិមាយំ
ពណ៌នាថា "ខ្ញុំជីវិតអញ្ចឹងអើយ! ព្រឹកស្អែក១នេះនរណាទៀយ
នឹងទៀរបង់បាន តែកើតទៀងហើយ ទម្រែងតែងស្លាប់ជាធម្ម
តាតែថាត្រង់ជីវិត១នេះ ទោះបង់បាត់ទៅក្តី ក៏មិនសូវជាសោក
ស្តាយអ្វីប៉ុន្មាន មកសោកស្តាយតែវិជ្ជា១ដែលខ្លួនបានចេះហើយ
ពុំទាន់បានបង្ហាត់បង្ហាញនរណាមួយសោះ អស់មាននរណាមួយ
ក្នុងលោកនេះ អាចចេះតទៅទៀតបានទៀយ"។

កាលនោះមាននាយភូឃុំម្នាក់បានឮ ចៅនោះយំពណ៌នាសោក
ស្តាយវិជ្ជាដូច្នោះ ក៏ចូលទៅសាកសួរថា "ចៅឯងព្រឹកនេះដល់
ទីស្លាប់ប្រាកដហើយ ចៅយំទៀបរាប់ថាត្រង់ជីវិត រូបកាយមិន
សូវជាស្តាយប៉ុន្មានមកស្តាយតែវិជ្ជា១ ដែលចេះមក តើវិជ្ជានោះ
ឈ្មោះវិជ្ជាអ្វី ចៅចេះវិជ្ជាអ្វី ចូរប្រាប់យើងមើល"។

ឯអ្នកទោសក៏ប្រាប់ថា "ខ្ញុំបានចេះវិជ្ជាដឹងភាសាសត្វវិជ្ជានេះ

វិសេសរបស់ខ្ញុំបានណាស់ ក្នុងលោកនេះគ្មាននរណាចេះសោះ
តែខ្ញុំបានដល់ទីស្លាប់ហើយវិជ្ជានោះសូន្យជាមួង ព្រោះពុំមាន
នរណាបានមកទៀនតទៅទៀយ"។ នាយភូឃុំឮដូច្នោះហើយ
នាំសេចក្តីនុ៎ះទៅជំរាបលោកខុកញ៉ាយោមរាជសព្វប្រការ ឯ
ខុកញ៉ាយោមរាជក៏នឹកក្នុងចិត្តថា វិជ្ជានេះវិសេសក្រៃពេក
ណាស់គួរតែទៀនយកទៅបនាំនាយភូឃុំទៅដោះអ្នកទោស
ចាកគ្រឿងចាំ ហើយសួរបញ្ជាក់ជាពិតឬពុំពិត ឯអ្នកទោសក៏
ជំរាបថាចេះពិតប្រាកដមែន ខុកញ៉ាយោមរាជថាយើងសុំទៀ
នតពីចៅឯងតើបានឬមិនបាន វិជ្ជានេះដល់ម្តេចប៉ុន្មាន។

អ្នកទោសថាខ្ញុំបាទ ជូនព្រះតេជព្រះគុណបានសូមព្រះតេជ
ព្រះគុណទៀនតទៅចុះ តែអត់អំពីខ្ញុំប្របាទនេះហើយវិជ្ជា
នោះនឹងសូន្យជាប្រាកដតែការនឹងទៀននោះតោងទៅតាំង
ពិធីទៀន នៅក្នុងព្រះវិហារចំពោះព្រះភក្ត្រព្រះបដិមាកនជា
ប្រធាន ក៏ឯគ្រឿងកំណល់គ្រែនោះមិនមានអ្វីច្រើនទេ ត្រូវការ
តែទៀន៥ ធូប៥ ផ្កា៥ប៉ុណ្ណោះឯង អញ្ជើញព្រះតេជព្រះគុណ
ទៀបទៀនឲ្យឆាប់ចុះ តែព្រឹកស្អែកខ្ញុំប្របាទលាព្រះតេជព្រះ
គុណទៅស្រុកខ្មោចហើយ។

ខុកញ៉ាំយោមរាជក៏ធ្វើតាមទើបឲ្យនាយភូឃុំនាំខ្លួនអ្នក
ទោសទៅឯវត្ត ដល់ហើយក៏នាំចូលទៅក្នុងព្រះវិហារ ឲ្យបិទ
ទ្វារវិហារជិតទាំងអស់ ពុំឲ្យមនុស្សណាមួយឮទៀយ ខុកញ៉ាំ
យោមរាជក៏ទៀបទៀនធូបលាជផ្កាតាំងនៅចំពោះព្រះភក្ត្រ
ព្រះ ហើយថាវិធីទៀននោះតើដូចម្តេចខ្លះ ចូរទៅបង្គាប់ទៅ
មើលយើងនឹងធ្វើតាម អ្នកទោសបង្គាប់ឲ្យអុជទៀនធូបហើយ
ឲ្យលោកយោមរាជ នឹងខ្លួនវាក្រាបថ្វាយបង្គំព្រះ សូត្រនមស្ស
ការពុទ្ធគុណ ធម្មគុណ សង្ឃគុណ ចប់ចុះហើយ អ្នកទោសប្រណម្យ
ដៃពោលដង្ហោយទៀយថា "ឱព្រះដ៏មានបុណ្យព្រះគុណប្រកប
ដោយព្រះមហាករុណា តែងប្រោសមេត្តាសត្វ ដែលកើតមាន
ក្តីវិបត្តិចូលមកពឹងពោធិសម្ភារ ជួយដោះទុក្ខសត្វឲ្យសត្វបានក្តី
សម្រាន្តទាំងលោកនេះនឹងបរលោក ព្រះគុណអើយខ្លួនខ្ញុំព្រះ
ករុណានេះត្រូវទៅទោសធំ ព្រឹកស្អែកនេះហើយលោកខុកញ៉ាំ
យោមរាជ នឹងឲ្យនាំទៅប្រហារជីវិតខ្ញុំព្រះករុណាៗមានក្តី
ភិតភ័យខ្លាចក្តីស្លាប់នោះជាបំផុត ស្តាយជីវិតក្រៃពេកណាស់
ព្រះគុណអើយ សូមព្រះអង្គទ្រង់ប្រោសបិណ្ឌបាតជីវិតខ្ញុំព្រះ
ករុណាអំពីលោកខុកញ៉ាំយោមរាជនេះ ឲ្យលោកប្រោសលែង

ខ្ញុំឲ្យរួចចាកក្តីស្លាប់ក្នុងគ្រាមុងនេះថាហើយ អ្នកទោសវាទៅ
ក្រាបទៀបបាទដើងលោកយោមរាជហើយដង្ហោយថា "ឱព្រះ
តេជព្រះគុណអើយ! សូមប្រោសអត់ទោសខ្ញុំប្របាទចេះ ហេតុ
ដែលខ្ញុំប្របាទយំសោគពោលថា ស្តាយវិជ្ជាចេះភាសាសត្វនោះ
ខ្ញុំមិនចេះវិជ្ជានោះទេតើខ្ញុំសោកស្តាយជីវិតពីតៗ គឺតបញ្ជូត
ឲ្យព្រះតេជព្រះគុណ អញ្ជើញមកកាន់ព្រះវិហារនេះឯងដើម្បី
ឲ្យព្រះសម្មាសម្ពុទ្ធជាម្ចាស់ពគីព្រះពុទ្ធរូបនេះឯង ទ្រង់បិណ្ឌបាត
ជីវិតខ្ញុំប្របាទ អំពីព្រះតេជព្រះគុណ ឱព្រះតេជព្រះគុណអើយ
ប្រោសថ្វាយជីវិតខ្ញុំប្របាទ ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទៅ
ឥឡូវទៀព្រះអង្គទ្រង់បិណ្ឌបាតហើយ ព្រះគុណអើយ! ការបូជា
ដោយគ្រឿងអាមិសទានឯទៀតៗនោះមានផលានិសង្ស ពុំស្មើ
នឹងការបូជាជីវិតខ្ញុំប្របាទ ដល់ព្រះពុទ្ធជាម្ចាស់ក្នុងគ្រានេះទៀយ ផលនេះហើយជាផលយ៉ាងធំបំផុត ព្រះតេជព្រះគុណនឹង
ប្រាថ្នាសាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាចសម្រេចដូចក្តីប្រាថ្នា
សាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាសម្រេចដូចក្តីប្រាថ្នាទៅអនា
គតកាល"ៗ ឯលោកខុកញ៉ាំយោមរាជ លុះឮពាក្យអ្នកទោស
ពោលដង្ហោយដូច្នោះ ក៏ដូចជាគេខ្វាស់ណែនឱនគឹកយើញថា

ចាញ់ កលខ្មបាយអ្នកទោសជាប្រាកដ ទើបនិយាយទៅកាន់
នាយភូឃុំថា "អើយើងចាញ់កលអ្នកទោសនេះហើយ ឥឡូវ
ទាំពោលពាក្យដង្ហោយសូមជីវិតទាំតព្រះពុទ្ធរូប ទាំអង្វរព្រះពុទ្ធ
ថាឲ្យទ្រង់បិណ្ឌបាតទោសទាំតឯងជាម្តង ការនេះតែយើងមិន
លែងទាំ ក៏ដូចជាយើងមិនយល់ដល់ព្រះពុទ្ធជាម្ចាស់ហាក់ដូចជា
យើងឥតសទ្ធា ក្នុងព្រះពុទ្ធសាសនាបើដូច្នេះនាយភូឃុំ យើងពីរ
នាក់ចូលសទ្ធាលើកជីវិតទាំថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចុះ
ហើយយើងពីរនាក់ទទួលកែខៃជាក្រោយ តែយើងបិទបាំងឲ្យ
ជិតកុំឲ្យខ្វះខ្វាយឮដល់ត្រចៀកអ្នកដទៃឯទៀតទៅឡើយ"។

ឯនាយភូឃុំក៏ព្រមតាម ទើបលោកយោមរាជឲ្យនាយភូឃុំ
ស្រាយគ្រឿងចង់ហើយថា យើងលែងចៅឯងហើយ ចូរចៅឯង
រត់ទៅនៅទីណាមួយគួរនរកជ្រាជីវិតចៅឯងចុះ ហើយកុំនិយាយ
ប្រាប់គេថាយើងដោះលែងចៅឯង ចៅឯងចូរថាកាច់ច្រនាក់
រត់ចាកគុកទៅចុះ តទៅមុខទៀត ចៅកុំប្រព្រឹត្តការលាមក
យ៉ាងនេះទៀតទៅឡើយ"។ ឯអ្នកទោសក៏ក្រាបថ្វាយបង្គំព្រះ
ហើយក្រាបលោកយោមរាជ និងនាយភូឃុំហើយក៏រត់ចេញទៅ
នៅស្រុកក្រៅ លាក់ខ្លួនពុំឲ្យពួកនរាជការដឹងឮទៀតឡើយ។

ឯខ្មកញ្ជ្រោយោមរាជក៏នាំនាយភូឃុំថ្វាយបង្គំលាព្រះពុទ្ធរូប
ហើយវិលទៅកាន់លំនៅៗជាសុខសប្បាយកំចាយតែសព្វប្រាប់
គេថាអ្នកទោសនោះកាច់ច្រនាក់រត់ចាកគុកទៅបាត់ហើយ។
លុះនៅកន្លងកាលយូរមក ទើងនោះពុំស្លាត់បាត់ទៅទៀយជា
ហេតុឲ្យដឹងឮទៅដល់ខ្មកញ្ជ្រោពលទេបៗ មានចិត្តត្រេកអរ
ដោយសមតាមគំនិតដែលគិតរកឱកាសនឹងក្រាបទូលព្រះរាជា
ឲ្យដកជានខ្មកញ្ជ្រោយោមរាជនោះបង់ អាត្មានឹងបានទីនោះ។
មានកាលសម័យថ្ងៃមួយជាពេលាព្រឹក ព្រះរាជាស្តេចចេញអង្គា
សភត្ត គឺដាក់បាត្រលោកសង្ឃស្តេចកំពុងទុកបាត្រ មានហ្វូង
ក្អែកទាំងឡាយហើរមកស្រែកកញ្ជ្រៀវឱកងរំពងទាំងផ្ទៃទាំង
ក្អែកពួកខ្លះហើរស្រែកយំ ទំតាមដើមឈើតាមដំបូលប្រាសាទ
ដំណាក់ទីទៃ។

ឯព្រះបរមចក្រី លុះស្តេចទុកបាត្រសូទេចហើយទ្រង់ត្រាស់
ថា អាសត្វក្អែកអស់នេះមានហេតុភេទអ្វីបានជាថ្ងៃនេះ ទាំនាំ
គ្នាមកស្រែកគឹកងកោលាហលយ៉ាងនេះ ធ្វើម្តេចនឹងបានដឹងភា
សាទាអេះ។

ឯខ្មកញ្ជ្រោពលទេពអង្គុយគាល់នៅទីនោះ លុះបានឮព្រះបន្ទូល

ដូច្នោះបានឱកាសទើបក្រាបទូលទៀងថា "សូមទ្រង់ព្រះមេត្តាប្រោស មនុស្សយើងទាំងឡាយក្នុងព្រះនគរនេះពុំមាននរណាមួយ អាចចេះភាសាសត្វទៀយឮថាអ្នកឱកញ្ញាយោមរាជគេចេះភាសាសត្វ ដោយគេបានរៀនតរំពីអ្នកទោសដល់ទីប្រហារម្នាក់ ហើយបានលែងអួលទោស ជាគ្រូគេនោះបង់សូមទ្រង់ព្រះមេត្តាប្រោស ឲ្យហៅមកសួរគង់ទ្រង់ជ្រាប"។ ព្រះរាជាបានទ្រង់ព្រះសណ្តាប់ដូច្នោះក៏ប្រើរាជបំរើម្នាក់ ឲ្យទៅហៅឱកញ្ញាយោមរាជចូលមកគាល់ ឯឱកញ្ញាយោមរាជ ឮថាទ្រង់មានព្រះរាជឱ្ការឲ្យហៅទៅគាល់ដូច្នោះ ក៏នឹកពិកាលក្នុងចិត្តថា ទ្រង់ឲ្យរកខ្លួនចូលទៅនេះ សូម្បីមានការប្លែកប្រាកដទើបសួរទៅកាន់រាជបំរើនោះថា នាហ្នឹនណាគាល់នៅក្នុងទីនោះខ្លះរាជបំរើជំរាបថា លោកឱកញ្ញាពលទេពគាល់នៅទីនោះ ឱកញ្ញាយោមរាជឮដូច្នោះ ក៏ដឹងខ្លួនថា អាពលទេពវាគង់ក្រាបទូលពោលទោសអញជាប្រាកដ តែតហើយឱកញ្ញាយោមរាជទៀបអាត្មាម្ចាស់ទៅជាមួយនឹងរាជបំរើនោះ លុះដល់ហើយក៏ចូលទៅក្រាបបង្គំអង្គុយគាល់ក្នុងទីដ៏សមគួរ ឯព្រះរាជាទតឃើញឱកញ្ញាយោមរាជចូលមកគាល់ហើយ ក៏ត្រាស់ថា "អើអ្នកយោមរាជ

ឥឡូវនេះឱកញ្ញាពលទេពគេប្រាប់យើង ថាអ្នកឯងបានរៀនភាសាសត្វអំពីអ្នកទោសម្នាក់ បានលែងអ្នកទោសនោះចេញចាកគុកទៅឥឡូវនេះហ្វូងសត្វក្អែកទាំងឡាយវាមកស្រែកកញ្ជ្រៀវកងរំពងជាកោលាហល យល់ជានឹងមានហេតុអ្វីមួយពុំខាន បើដូច្នេះអ្នកឯងចេះភាសាសត្វចូរស្តាប់វានិយាយគ្នាទៅមើល"។ ឱកញ្ញាយោមរាជក៏ទទួលព្រះឱ្ការទូលអនុលោមតាមថា ខ្លួនបានរៀនបានចេះដឹងភាសាសត្វពិតប្រាកដមែន លុះឮព្រះឱ្ការប្រើឲ្យស្តាប់សព្ទក្អែកដូច្នោះ ក៏ធ្វើដាំបែរទៅស្តាប់សព្ទក្អែកម្ខាងទៀត លុះស្ងប់សព្ទក្អែកបន្តិច ក៏ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ហ្វូងក្អែកដែលទំលើដើមឈើនោះជាហ្វូងក្អែកស្រុកក្រៅ ឯហ្វូងក្អែកដែលទំលើដំបូលមហាប្រាសាទនោះ ជាហ្វូងក្អែកនៅក្នុងក្រុងនេះ។ ព្រះរាជាឮដូច្នោះក៏ត្រាស់សួរទៅវិញថា "ចុះក្អែកស្រុកក្រៅវាមកយំកងតើវាយំថាដូចម្តេច? ក្អែកក្នុងក្រុង តើកញ្ជ្រៀវថាដូចម្តេច?។ អ្នកឱកញ្ញាយោមរាជក្រាបទូលថា "ក្អែកស្រុកក្រៅមានក្តីក្តៅក្រហាយដោយអ្នកស្រុកក្រៅ ពុំបានធ្វើបុណ្យឲ្យទានដូចអំពីឆ្នាំមុនៗ គឺឆ្នាំមុនៗអាណាប្រជានុរាស្ត្រសំបូណ៌ស្រួរអង្កូរគេនាំគ្នា

ធ្វើបុណ្យ និមន្តលោកសង្ឃឆាន់តាមភូមិលំនៅឯចំណីអាហារ
ដែលសេសសល់នោះ គេបោះឲ្យទានក្អែកឬសត្វទៀតៗផង
បណ្តាលសត្វទាំងឡាយមានក្អែកជាដើម សឹងបានបរិភោគចំណី
ដែលសល់នោះទួទៅ សេចក្តីសុខសប្បាយក៏មានគ្រប់តំបន់
ឥឡូវនេះឆ្នាំនេះ លោកឧកញ៉ាពលទេពជានាយកេរ្តត្រចាត់មេកង
អាជ្ញាលួងចេញទៅកត់ស្រូវ ធ្វើមិនត្រូវតាមប្រទៃណីគឺយកពន្ធ
ពីនាស្តលើសប្រមាន ធ្វើមិនត្រូវតាមប្រទៃណីគឺយកពន្ធពីនាស្តុ
លើសប្រមាណ នាស្តុគ្នាមានស្រូវតែត្រឹម ៤ ៥ ថាំងក៏កត់គ្នាឲ្យ
ជាប់ដែនឧកញ៉ាពលទេពឲ្យកត់ដល់ទៅស្រូវពូជ ស្រូវដំណើប
ស្រូវចំការប្រាំង យកជាពន្ធទាំងអស់ មួយទៀតស្រូវគ្នាមានត្រឹម
៥០ ៦០ ភីទាយបង្កើនដាក់ជា ៨០ ១០០ នាស្តុគ្នាតវ៉ាក៏មិនបាន
យកបុណ្យសក្តិសង្កត់បង្ក្រូបគ្នាទៅតាមអំពើចិត្តផ្ទេរៗ ពួក
អាណាប្រជានុនាស្តុកើតក្តីក្រលំបាកបានក្តីក្តៅក្រហាយតែឥល់
ៗគ្នាបានជាឆ្នាំនេះមិនមាននរណា អាចធ្វើបុណ្យឲ្យទានដូចឆ្នាំ
មុនៗបាន ពួកក្អែកទាំងឡាយពុំបានទទួលទានបាយសម្ពដែល
សេសសល់អំពីការបុណ្យទាននោះឯង ទើបវានាំគ្នាចូលមកក្នុង
ក្រុង ដើម្បីថ្លែងសេចក្តីលំបាករបស់នាស្តុដល់ពួកក្អែក បណ្តា

ផាញ្ជាតិនៅក្នុងក្រុងឲ្យពួកក្អែកក្នុងក្រុងនាំសេចក្តីក្តៅក្រហា
យទៀង ក្រាបបង្គំទូលព្រះកនុណាជាម្ចាស់ផ្ទៃក្រោមឲ្យទ្រង់
ជ្រាប ។ ការឧកញ៉ាពលទេពប្រព្រឹត្តខុសព្រះបញ្ញត្តិមានសភា
ពយ៉ាងនេះ សូមល្អងធ្លុះព្រះបាទស្តេចទ្រង់ជ្រាប" ។

ឯព្រះបរមនាដា បានទ្រង់ព្រះសណ្តាប់ពាក្យឧកញ៉ាយោម
នាជដូច្នោះក៏ត្រូវព្រះទ័យទើបទ្រង់ខ្វាល់នឹងឧកញ៉ាពលទេព
កោតឆនាស្តុ ធ្វើឲ្យនាស្តុក្តៅក្រហាយទាំងព្រះនាជអាណាខេត្ត
ស្តេចទ្រង់ឲ្យដកជានេ ឧកញ៉ាពលទេពចេញចាកមន្ត្រី ប្រោស
ប្រទានឧកញ៉ាយោមនាជទៀងទីជា សម្តេចចៅហ្វាទទួរអគ្គម
ហាមសេនា ស្តីនាជការចៅក្រសួងអធិបតី ។

ចប់សេចក្តីតែត្រឹមនេះ

ទៀងនិទាននេះ បានគិតដល់បុគ្គលទុច្ចរិតគិតប្រទូសន៍យដល់
បុគ្គលអ្នកឥតទោស បទលោកថា "បុគ្គលចងប្រទូសន៍យដល់
គេ ដែលពុំមានទោសអ្វីនឹងខ្លួនហើយ ទោសនោះត្រូវទំលាក់មក
លើខ្លួនឯងវិញ" ដូចយ៉ាងឧកញ៉ាពលទេព គិតប្រទូសន៍យឧក
ញ៉ាយោមនាជនោះឯងឧកញ៉ាយោមនាជមានប្រាជ្ញាទទួល
ពាក្យខ្លួនចោទ គឺពលទេពក្រាបទូលថាយោមនាជចេះភាសាសត្វ

គេក៏ទទួលថាចេះដូចពាក្យខ្លួនថាដល់ស្តេចប្រើគេឲ្យស្តាប់សព្ទ
ភាសាក្អែក គេទទួលស្តាប់ ហើយគេថាក្អែកវានិយាយអំពីទោស
ខ្លួនទៅកំហែងរាស្ត្រ បើខ្លួនប្រកែកថាមិនមែនវិញ នរណានឹង
ទៅដឹងភាសាក្អែកជា២-៣ នាក់ផងនឹងយកជាសាក្សីថាមិនមែន
នោះ ដ្បិតខ្លួនថាគេចេះហើយគេចេះតែម្នាក់ឯងនឹងមាននរណា
ទៅចេះដឹងផងៗ ខ្មកញ្ជ្រោលទេបទាល់ចំណេះខ្លួនឯង បានជា
ពុំហ៊ានប្រកែកតវ៉ានឹងខ្មកញ្ជ្រោយោមរាជក្នុងកាលនោះ មួយ
ទៀតពាក្យឯណា ការឯណា ដែលខ្លួនបាននិយាយមុសាទៅហើយ
តោងកុំគេចកុំទើរុះ ត្រូវទៅប្រកាន់ការនោះឲ្យមាំដូចយ៉ាងខ្មកញ្ជ្រោ
យោមរាជ នឹងបានទៀនចេះភាសាសត្វនោះកាលណា តែខ្លួនចាញ់
កលអ្នកទោសនោះទេតែដល់ពេលទេពក្រាបទូលថាចេះភាសា
សត្វ គេក៏ទទួលថាចេះមែន ហើយគេនិយាយដាក់ទំលាក់ទោស
មកលើខ្លួនឯងវិញ ខ្លួននឹងទើថាមិនមែនវិញឯណាក៏បានៗ
អ្នកមានបញ្ញាត្រូវពិចារណាទៅទៀតចុះៗ

ចប់តម្រាអនុលោមតាមហេតុទី ២៩។

ទើរឯឆ្នាស្រុក១ នឹងចាបពូក១

មានឆ្នាស្រុក១ ចាបពូក១ នាយគេចិញ្ចឹមនៅជាមួយគ្នាថ្ងៃ១
មានចាបព្រៃ១ ហើរមកទំនៅទីជិតនៃចាបពូកនោះ ហើយពោ
លពាក្យតិះដៀលចាបនៅក្នុងទ្រុងជាភាសាសក្កណជាតិ ឯចាប
នៅក្នុងទ្រុងក៏កើតទោសោទៀង តាំងដៃនប្រទេចទៅចាប
ព្រៃទើរុញចាបទាំងពីរកើតជម្លោះដៃនគ្នាទៅទើរុញទៅមកតែនឹង
ប្រចឹកគ្នាពុំបាន ព្រោះ១នៅក្នុងទ្រុង១ នៅក្រៅទ្រុងៗ
ឯឆ្នាស្រុក បានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏ខឹងនឹងចាបព្រៃ
ថា អាសត្វចង្រៃហេតុអ្វីវាមកឈ្លោះប្រកែកនឹងចាបជាសំឡាញ់
អញអេះ បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ គឺតហើយ
ឆ្នានោះលបទៅចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីសាច់ចាប
ព្រៃកើតក្តីឆ្នាញ់ពិសា ទើបថាអញមិនដឹងថាសាប់ចាបព្រៃមាន
រសជាតិឆ្ងាញ់ដល់ម្ល៉ះសោះ បើដូច្នេះចាបដើមតាំងពីថ្ងៃនេះ
ទៅអញនឹងស្វែងចាប់ចាបព្រៃអាស្រ័យជាចំណីខ្លួន ឆ្នានោះគឺត
ដូច្នោះហើយ ពីថ្ងៃនោះមកតាំងស្វែងលបចាប់ចាបព្រៃអាស្រ័យ
ជានិរន្តរ៍ ថ្ងៃមួយឆ្នានោះរកចាប់ចាបព្រៃពុំបាន តើតញ្ជ្រោម
មាត់អត់ពុំបាន ទើបហែកទ្រុងចូលទៅចាប់ចាបជាសំឡាញ់

បវិភោគតាមក្តីប្រាថ្នាខ្លួនហោង។

ទៀងនេះ បានគតិដល់បុគ្គលជានាហ្នឹនធំឬចៅហ្វាយស្រុក ដែលពុំធ្លាប់លក់នាស្តុប្រជាម្តងសោះនោះអធ្យាស្រ័យក៏ល្មមសមគួរ តែបើបានលក់នាស្តុបានប្រាក់មាសម្តងហើយ តែតញ៉ាមអត់ពុំបានដល់ក្រោយមិនយល់មុខនរណា ចេះតែលក់ទាំងអស់ទោះសាច់ញាតិសន្តានខ្លួនក្តី ក៏ចេះតែលក់មិនទើសមុខថានរណាទៀយ តែតដោយញ៉ាមបាន ដូចយ៉ាងឆ្នាស្រុកស៊ីចាបសំឡាញ់ខ្លួននោះឯង។

ចប់តម្រាគតិញ៉ាមមាត់អត់ពុំបានទី ៣០។

ទៀងសត្វសំពោចចូលក្នុងជង្រុកស្រូវ

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វសំពោចមួយ ចូលទៅក្នុងជង្រុកស្រូវគេបាននៅស៊ីស្រូវដាដល់សនៃន:ធាត់ធំ។

ថ្ងៃមួយអ្នកម្ចាស់ជង្រុក ដើរមកត្រង់ទីជង្រុកនោះដោយមានកិច្ចនឹងទៅស្រែ ឯសំពោចនៅក្នុងជង្រុកបានឮសូន្មឹកជើងមនុស្សដើរមកដូច្នោះ ក៏ភិតភ័យតក់ស្លុត សុះទត់មកត្រង់បង្អួច ដើម្បីនឹងចេញតាមចន្លោះមេចន្ទឹង តែចេញពុំរួចទៀយទើបពោលទៀងថា កាលអញចូលមក ក៏ចូលតាមចន្លោះមេ

ចម្រឹងនេះឯង មេចន្ទឹកនេះសោត ក៏នៅជាប្រក្រតីចុះហេតុអ្វីបានជាចេញទៅពុំរួចដូច្នេះ។ គ្រាកាលនោះមានកណ្តុរមួយទាមកខាងមេចន្ទឹង បានឮសំពោចនោះពោលពាក្យដូច្នេះក៏ឆ្លើយថាមេចន្ទឹងនេះនៅដដែលដូចមុនទេ ប៉ុន្តែគ្រាកាលបងឯងចូលមកនោះតូរបបងស្គមតូចទើបចូលមកបាន លុះបងឯងមកនៅក្នុងជង្រុកនេះ បានបវិភោគស្រូវឆ្អែតស្កប់ស្កល់អត្តភាពបងឯង តែតធាត់ធំទៀងលើសមុន ហេតុនេះបានជាចេញទៅពុំរួច នែបងឯងកុំស៊ីស្រូវតទៅទៀត ស៊ូអត់ត្រាអត្តភាពស្គមតូច ដូចកាលមុននោះ ទើបបងឯងអាចចេញទៅរួចបាន។ សំពោចបានស្តាប់ពាក្យកណ្តុរ ថ្លែងដូច្នោះក៏ចូលចិត្តបានទើបតាំងអត់អាហារពីថ្ងៃនោះមក ទាល់តែស្គមតូចដូចមុនទើបចេញអំពីជង្រុកនោះទៅបាន។

ចប់សេចក្តីតែប៉ុណ្ណោះហោ។

ទៀងនេះ បានគតិដល់បុគ្គលអ្នកចូលធ្វើរាជការបានទទួលទានបៀវត្សប្រាក់ខែតែតមានសម្បត្តិបរិបូណ៌ ហើយចង់លែងធ្វើរាជការទៀ នោះមានតែលែងទទួលប្រាក់ខែបង់ ទើបអាចចេញចាកនាទីនៃរាជការទៅបាន មួយទៀត បុគ្គលចង់ចេញ

ទៅបួសជាភិក្ខុ សាមណេរសោត នោះមានតែលះសម្បត្តិទ្រព្យចោលបង់ ស៊ូអត់កុំបរិភោគបញ្ចកាមគុណនោះទើបចេញទៅបួសជាភិក្ខុ សាមណេរបាន។

បទអស់នេះ អ្នកប្រាជ្ញគប្បីពិចារណាទៅទៀតចុះ។

ចប់តម្រាគតិរើខ្លួនចេញចាកទុក្ខទី ៣១

ទៀងឈ្មួញលក់លានឹងពួកចោរព្រៃ

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មាននាយឈ្មួញម្នាក់មកអំពីប្រទេសក្រៅ នាំកូនឈ្មួញដឹកលាបរលា លិលាតាមផ្លូវទៅលុះមកដល់ទឹកណ្តាលព្រៃស្ងាត់ មានពួកចោរទាំងឡាយនៅចាំលួចចាំប្លន់មហាជនដែលដើរទៅមកក្នុងផ្លូវនោះ។ ថ្ងៃនោះ ពួកចោរបានឃើញនាយឈ្មួញមកដល់ទឹកនោះក៏នាំគ្នាចួលទៅយប្លន់នាយឈ្មួញៗមានគ្នាតិច ស៊ូនឹងពួកចោរនោះពុំបាន ទើបនាំគ្នាទៅកាន់ទិសានុទិសផ្សេងៗ។ ឯពួកចោរក៏នាំគ្នាចោមចាប់លាជាពាហន:លាឯណាដែលមិនមានទ្រព្យរបស់នៅលើខ្នង ពួកចោរពុំត្រូវការចាប់យកទៅឡើយ គឺចាប់តែលាដែលមានទ្រព្យរបស់ជាប់នៅលើខ្នង។ កាលនោះពួកចោរចាប់បានលាឈ្មោល១មានទ្រព្យលើខ្នង ហើយនាំគ្នាដឹក

ទាញទង់ទៅកាន់លំនៅវិញ លាឈ្មោលបានក្តីទុក្ខទៀតនាដោយចោរវិញវិញ វិញទាញទៅឥតក្តីមេត្តាទើបមកគិតថា ពួកលាទាំងឡាយបណ្តាដែលមកជាមួយគ្នា គេសឹងផុតពីកណ្តាប់ដៃពួកចោរអស់នេះគឺវាពុំត្រូវការ ឯងចាប់នឹងចងយកព្រោះគេគ្មានរបស់ទ្រព្យជាប់នៅលើខ្នង ដូចរូបអាត្មានេះ អាត្មាអញបានក្តីទុក្ខទោសយ៉ាងនេះ ក៏ព្រោះរបស់ទ្រព្យជាប់នៅលើខ្នងនេះ ឯងគឺតទៅទ្រព្យសម្បត្តិមាសប្រាក់កែវកងទាំងពួងនេះ ជាគ្រឿងនាំឲ្យកើតទុក្ខទោស គឺជាអាសីវពិស ចឹកអាត្មាឯងប្រាកដ។ លាឈ្មោលនោះគឺតឃើញក្តីទុក្ខទោសអាត្មាដូច្នោះហើយ ក៏យំសោកវិយោគ ដើរតាមពួកចោរនោះទៅ ដរាបដល់លំនៅនៃចោរហោង។

ទៀងនេះ បានគឺដល់បុគ្គលអ្នកមានទ្រព្យសម្បត្តិមិនចេះប្រយ័ត្ន សម្បត្តិនោះជាពិសពោរពេញខ្លួនវិញ ដូចយ៉ាងនិទាននាងនារីម្នាក់ ពាក់ខ្សែមាសទំហូរពេជ្រ កង ចិញ្ចៀន ខ្សែដៃតែងអាត្មាបង្ហូតគេបង្ហូរកាមតាមការលោភិយ ចុះដោយសារកប៉ាល់មកពីស្រុកទន្លេធំ លុះមកដល់ក្រុងភ្នំពេញ នាងនោះក៏ទៀងចាកនាវា យាត្រាកត្រង់ក្រោយទំនួខ្ពស់ណោះលោមកាលនោះ

មានអារអ្នកលេងម្នាក់ឃើញនាងនារីដើរមកដល់ទីបានឱកាសហើយ ទើបទាក្លែងជាស្វាមីនៃនាងនោះ ស្ទុះទៅទាយធាក់ដោះយកខ្នែកឯចាន័ដេរស្តីថា ខ្មោចមេចក្រែអប្រិយ អញជាប្តីទាមិនស្តាប់ពាក្យអញឃាត់ខ្លះ គួរឬទាចចេសចេះតែទៅចោលឲ្យអញនៅចាំផ្ទះ រកក្រកូនពិបាកស្ទើរនឹងស្លាប់ បើដូច្នេះឲ្យគ្រឿងខែ្នមាសទាពាក់ធ្វើអ្វី ត្រូវអញអូសយកពីហឯងឯងវិញ កុំឲ្យជំនាទាពាក់ទៅទៀយដេរហើយ អានោះទានត់សំដៅកាន់ផ្លូវទៅខាងក្រុងគុកគេចខ្លួនបាត់ទៅហោង។

ឯនាងនារីដួលចុះ ក្រោយក្រោកទៀងបានហៅគេឯងជួយចាប់ចោរប្តន់ ក៏ពុំមាននរណាមួយចូលជួយទៀយ ព្រោះគេឮពាក្យអាចោរដេរប្រទេចជាទំនងប្តីប្រពន្ធ គេនឹកស្មានថាប្តីគេប្រពន្ធគេ ដេរទាយគ្នាដូចធម្មតា បានជាគ្មាននរណាមួយជួយទៀយ។ លុះអាចោរនត់ទៅបាត់ហើយ ទើបនាងនោះប្រាប់គេថាមិនមែនប្តីខ្លួនទេ ជាចោរទាយដណ្តើមយកគ្រឿងមាសខ្លួនប្រាកដ។ នាងនោះប្រាប់ឲ្យគេជួយដេញចោរនឹងចាប់ទា ក៏ចាប់ទាពុំបានទៀយ ព្រោះទាទៅបាត់ឃ្លេនហើយ នាងនារីក៏បានក្តីទុក្ខទោសដូចគ្នានឹងរឿងលាដែលបានពណ៌នាមកនេះ។

អ្នកប្រាជ្ញគប្បីដឹងដោយប្រការដូច្នេះ។

ចប់តម្រាកតិមានទ្រព្យជាប់ទោសមានប្រាក់មាសវិនាសរូបទី ៣២។

រឿងលានឹងឆ្កែមានចៅហ្វាយជាមួយគ្នា

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មាននាយដង្ហៅម្នាក់ផ្ទុកគ្រឿងសៀងអាហារក្នុងតាងដាក់លើខ្នងលា មានសុនខស្រុកមួយទៅជាមួយគ្នា លុះទៅដល់ទីទាលមួយមានដើមឈើដុះលេ្បាះៗ នាយដង្ហៅនោះក៏ឈប់សម្រាកកំលាំងដោយពេលានោះជាពេលថ្ងៃត្រង់ ទើបចូលដេកសម្រាកក្រោមដើមឈើធំ លែងសត្វលាឲ្យស៊ីស្មៅប្រើឆ្កែឲ្យនៅឃ្លាលា និងឲ្យមើលហេតុអន្តរាយឯទៀតៗផង។

ឯសុនខកើតឃ្លានបាយក៏និយាយនឹងលានោះថា "ភ្ញីនអើយ គ្នាឃ្លានបាយណាស់ចូរឯងឱនខ្លួនចុះបន្ទាបខ្លួនបន្តិច ឲ្យគ្នាយកបាយក្នុងតាងតោះអាស្រ័យ"។ ឯលាឮឆ្កែសុំយកបាយដូច្នោះក៏មិនចង់ឲ្យដោយខ្លាចនាយផង ទើបតបថា "ពេលនេះមិនត្រូវចៅស៊ីទេ ចាំដល់ល្ងាចសិនសឹមយើងដាក់ឲ្យស៊ី"។

សុនខក៏អង្វរថា "គ្នាឃ្លានណាស់ចាំល្ងាចពុំបានទេ ចូរភ្ញីនដាក់មកឲ្យគ្នាស៊ីសិន"។ លាក៏តបទៅវិញថា "ចាំនាយគាត់ភ្ញាក់

សិនចុះ សឹមស៊ីទៀលានេះយើងមិនហ៊ានឲ្យទេ"។ សុនខនោះបានឮថាលាមិនព្រមឲ្យដូច្នោះក៏តូចចិត្តគិតខឹងនឹងលា តែពុំហ៊ានថាអ្វីទៅទៀត។ ឯលានោះដើរកស៊ីស្មៅស៊ីស្លឹកឈើទៀងៗទៅដល់ជាយព្រៃធំ១។

កាលនោះមានឆ្កែព្រៃមួយ បានឃើញលាមកស៊ីស្មៅតែឯង ក៏បោលមកនឹងខាំលាជាអាហារ លាឃើញឆ្កែព្រៃដេញមក ដូច្នោះ ក៏ភិតភ័យតក់ស្លុតរត់មកត្រង់ឆ្កែស្រុក ហើយហៅឆ្កែស្រុកថាសំឡាញ់អើយជួយគ្នាផងឆ្កែព្រៃវាដេញខាំគ្នាហើយ។

ឯសុនខស្រុក ក៏ស្តីផ្ទាល់ទៅថា "អើលាអើយកាលអញសុំបាយស៊ីឯងថាចាំនាយគាត់ក្រោក ឥឡូវមានភ័យដល់មក អញចាំនាយគាត់មកដែរ ទើបអញជួយបាន" ថាហើយសុនខក៏ធ្វើជាពុំនាំពាតាំងអង្គុយនៅមើលតែពីចម្ងាយហោង។ ឯលាក៏ភិតភ័យក្រៃពេកណាស់ ឆ្កែព្រៃរឹតតែបោលខាំអំពីក្រោយត្របាក់កែងជុតៗ លានោះក៏រឹងរឹតតែភ័យខ្លាំង តាំងបោលបោះផ្លោះទៅឯដើមឈើធំ ដែលនាយដង្ហៅដេកនោះឯង ដល់ហើយក៏ស្រែកហៅនាយឲ្យជួយអាត្មាឯនាយដង្ហៅបានឮសូរលាស្រែកដូច្នោះក៏ភ្ញាក់ក្រោកទៀងម្ចុះបែរទៅឃើញឆ្កែព្រៃដេញខាំលា ក៏ស្រែក

ហៅសុនខស្រុកឲ្យជួយលាជាប្រញាប់។

ឯសុនខស្រុក បានឮនាយហៅឲ្យជួយលាដូច្នោះក៏សុះម្ចុះម្ចាបោលទៅដេញខាំឆ្កែព្រៃៗ ឃើញឆ្កែស្រុកក៏ខ្លាច ពុំអាចបោលដេញលាទៅទៀតទៅឡើយ សុះទត់ចូលព្រៃបោលទៅកាន់លំនៅអាត្មាវិញហោង។

ឯនាយដង្ហៅ កាលឆ្កែព្រៃបោលបាត់ទៅវិញហើយ ទើបហៅលានឹងឆ្កែស្រុកចូលមកសាកសួរហេតុនោះថា "លាឯងអញឲ្យទៅស៊ីស្មៅបានឲ្យឆ្កែទៅឃ្វាលជួយមើលក្តីអន្តរាយផង ឥឡូវឆ្កែព្រៃវាដេញខាំខ្លួន តែហេតុអ្វីខ្លួនក៏មិនទៅរកឆ្កែស្រុកឲ្យគេជួយ ត្រឡប់ជាបោលមករកអញវិញ អញបានផ្តាំថាឯងទៅរកស៊ីចុះ គ្នាសុំដេកសម្រាកកំលាំងបន្តិចល្មមដល់ពេលត្រជាក់បន្តិច នឹងលើកបរទៅទៀត"។

ឯលាក៏តបទៅវិញថា "កាលឆ្កែព្រៃវាដេញនោះខ្ញុំបាទបានរត់ទៅរកឆ្កែស្រុក បានស្រែកហៅឲ្យជួយ ឆ្កែស្រុកគេពុំជួយទៅវិញគេត្រឡប់ថាជានាយភ្នាក់សិនទើបគេជួយ ឆ្កែស្រុកគេពុំនាំពាយ៉ាងនេះ បានជាខ្ញុំបានរត់មករកនាយឲ្យជួយ"។ នាយដង្ហៅឮលាថាដូច្នោះក៏សួរទៅឆ្កែវិញថា "ម្តេចឯងមិនជួយលាអញ

បានផ្តាំផ្តាច់ថាឲ្យមើលក្តីអន្តរាយផង"។

ឆ្កែស្រុកឆ្លើយថាឲ្យការថា "កាលខ្ញុំបានឃ្លានបាយខ្ញុំបានសុំលា ថា គ្នាឃ្លានបាយណាស់ចូរឯងបង្ហោនខ្លួនចុះបន្តិច គ្នានឹងយកបាយ កកអាស្រ័យនោះលាពុំឲ្យទៅឡើយ គេថាចាំនាយភ្នាក់សិនសឹមស៊ី ចុះខ្ញុំបាននឹកខឹងនឹងលាយ៉ាងនេះ ដល់ឆ្កែព្រៃវាដេញលាមកលា ស្រែកហៅឲ្យខ្ញុំបានជួយ ខ្ញុំបាទក៏តបពាក្យគេវិញថា ចាំនាយ ភ្នាក់សិនសឹមជួយ ពាក្យខ្ញុំបាទថានោះគឺថាតែតាមពាក្យលា ដែលពោលមុននោះឯងសូមនាយជំនះក្តីនេះ ឲ្យឃើញខុសត្រូវ ដោយយុត្តិធម៌ចុះ"។ នាយដង្កៀសួរទៅលាវិញថា "អើលាហេតុ អ្វីឆ្កែគ្នាសុំបាយកកស៊ី មើចចៅមិនឲ្យវាស៊ីទៅហ៎ះ"។

លាតបទៅវិញថា "បានជាខ្ញុំមិនទាន់ឲ្យនោះព្រោះខុសកាល ពេលា គឺពេលព្រឹកលោកនាយនឹងឆ្កែនេះ បានបវិភោគទួច ហើយពេលថ្ងៃត្រង់លោកនាយមិនដែលពីសា។ តែដល់ពេល ល្ងាចតែម្តងទាក៏ស៊ីត្រូវទៅពេលនឹងនាយដែរ កាលឆ្កែទាសុំបាយស៊ី នោះគឺជាពេលថ្ងៃត្រង់ ឆ្កែឃ្លានឥតរបបខុសពេលនាយពីសា ហេតុនោះខ្ញុំឲ្យធ្វើម្តេចបាន។ជាខ្ញុំបាទថាចាំនាយលោកភ្នាក់ សិនសឹមឲ្យស៊ី បានជាខ្ញុំបានថាដូច្នេះ ព្រោះបាយត្រីអស់នេះជា

របស់ផងនាយ។ អនុញ្ញាតឲ្យទៅខ្ញុំបាទហ៊ានដាក់ឲ្យ នឹងចាត់ចែងឯងឲ្យដោយចិត្តឯងឯណាក៏បាន ទីស័យអ្នកនៅនឹងនាយ ចៅហ្វាយឬនៅនឹងសំណាក់ត្រូចារ្យ លោកឲ្យឯងទទួលទុកដាក់ សេ្បៀងអាហារ ឬទ្រព្យសម្បត្តិឯណានីមួយ ត្រូវតែរក្សាចែក ទាំងរបស់អស់នោះ កុំឲ្យវិនាសទៅដោយការមិនគួរបង់ចែមន បើនាយចៅហ្វាយឬគ្រូអាចារ្យលោកបង្គាប់ថាឲ្យនរណាៗ នោះទើបអាចនាំចេញឲ្យទៅអ្នកនោះៗ បានមួយទៀតអ្នក រក្សាទ្រព្យសម្បត្តិនាយចៅហ្វាយនេះត្រូវឲ្យដឹងវត្តនោះៗផង គឺវត្តណា ចំណីណាទុកយូរទៅពុំបាន ល្មមប្រាប់នាយឬកនាយ នឹងប្រាប់ពុំឃើញក្តី ក៏គប្បីយកមកចែកចាយឲ្យភ្ញៀនផងអាស្រ័យទៅក៏គួរ ព្រោះវត្តុចំណីនោះ ទុកទៅនឹងខ្ជូចអសារឥត ការចោលបង្ហែរត្រូវខ្ញុំបាទកាន់ច្បាប់យ៉ាងនេះ បានជាសុនខសុំ បាយស៊ីខ្ញុំបានមិនហ៊ានឲ្យ"។

ឯនាយដង្កៀបានឮពាក្យលាពោលត្រូវច្បាប់ដូច្នោះក៏ត្រេ អរទើបនិយាយទៅនឹងឆ្កែវិញថា "អើបាសុនខ លានិយាយឲ្យ ការនេះត្រូវច្បាប់ល្អហើយចៅឯង តែសុខចិត្តចាញ់ប្រៀបលា ហើយឬ។ ពុំសុខចិត្តយ៉ាងណាចូរថាទៀតចុះ"។ ឯសុនខក៏តបថា

"ខ្ញុំបាទពុំសុខចិត្តចាញ់លានេះទេ ព្រោះលាវាថាលោកនាយនឹងខ្ញុំបាទបរិភោគអាហារមានពេលា តែបរិភោគតែព្រឹកនឹងល្ងាចឯពេលថ្ងៃត្រង់ថ្ងៃរសៀលបរិភោគពុំបាន ចុះត្រង់រូបលានេះមើចក៏ស៊ីស្មៅ ស៊ីស្លឹកឈើតែវាលល្ងាច ព្រឹកក៏ស៊ី ថ្ងៃក៏ស៊ី ស៊ីគ្មានឈប់សោះ ត្រង់យើងម្តេចក៏ចាំបាច់មានពេលមានពេលានេះបទ ១ មួយទៀតពាក្យលាថា អ្នករកក្បាច្រៃព្យរបស់នាយចៅហ្វាយត្រូវដឹងវត្តុដែលទុកយូរបាននឹងទុកយូរមិនបាន វត្តុណាទុកយូរមិនបាននឹងខូចចោលនោះត្រូវអ្នករកក្បាច្រាប់នាយ ឬបើរកនាយនឹងច្រាប់មិនឃើញទេ ត្រូវនាំចេញមកឲ្យពួកភ្ងៀនអាស្រ័យសិនក៏គួរ អើដូចយ៉ាងបាយកកនេះ ជាវត្តុសំណល់សល់អំពីព្រឹក ទុកយូរទៅពុំបាននឹងផ្លែមខូចចោលបង់អើខ្ញុំបាទសុំបាយកកនេះអាស្រ័យ ហេតុម្តេចលាមិនឲ្យខ្ញុំបាទៗ នឹងបានសុំវត្តុដែលដែលទុកយូរបានឬចំណីថ្មោងកាលណាសូមលោកនាយពិចារណាត្រង់បងនេះឲ្យទាន តាមពាក្យដែលលាដោះស្រាយមកនោះមែល?ៗ

ឯលាបានឮផ្លែកែសំនួរស្របតាមពាក្យខ្លួនដូច្នោះក៏ឆ្លើយកាត់ទៀងថា "នែចៅសុនខ ឯពាក្យយើងថាខ្លួនលោកនាយនឹងតួចៅឯងបរិភោគមានពេលមានទៀលា ត្រង់យើងជាសត្វលាស៊ីស្មៅ ស៊ីស្លឹកឈើមិនមានពេលនេះ ព្រោះអាហារចំណីខុសគ្នាខាងចៅឯងបរិភោគបាយត្រី សាច់ ជាអាហារៗនេះតែបរិភោគឆ្អែតហើយ មិនបាច់ឈប់ទើមកទំពាអ្យងលំអិតទៀតទ្បើយ ឯងខាងយើងជាពួក គោ ក្របី បរិភោគស្មៅជាអាហារៗនេះតែបរិភោគឆ្អែតហើយ ត្រូវឈប់ទើចេញមកទំអ្យងទាល់តែល្អិត កាលល្អិតហើយ អាហារនោះតិចចុះមិនពេញពោះទៅទីញ្ញហេតុនោះ ទើបយើងពួក គោ ក្របី បរិភោគពុំមានពេលឈប់ឃ្យរដល់ល្ងាចបាន មួយទៀត តិណជាតិទាំងឡាយ សឹងដុះដាស់ពាសទួទៅទាំងធរណី បណ្តាលសត្វព្រៃក្តី សត្វស្រុកក្តី ត្រូវការអាស្រ័យ មិនចាំទីញ្ញដូរឬសុំនរណាទេ ត្រូវស៊ីបានឥតថ្លៃ ក៏ឯអាហារបាយ ត្រី សាច់ ចំណែកខាងមនុស្សឬសត្វដែលត្រូវស៊ីនោះ សឹងបានមកដោយទីញ្ញដូរតែទើបបានមក នឹងទៅបរិភោគឥតទៀលដូចយ៉ាងស្មៅនោះពុំបាន ជាការចុះទុនច្រើនៗនាំឲ្យបានក្តីក្រលំបាកទៅខាងមុខ មួយទៀត ទោះសត្វស៊ីស្មៅក្តី ស៊ីបាយក្តី តែមានម្ចាស់ចាត់ឲ្យស៊ីយ៉ាងណា ក៏តោងប្រព្រឹត្តតាមការនបស់ម្ចាស់នោះឯង មួយទៀត ឆ្អែពោលពាក្យថាបាយកក

ជាបាយសំណល់ជាវត្ថុទុកយូរពុំបានក៏ពិតមែន តែទុកទៅត្រឹមពេលល្ងាច ក៏មិនទាន់ផ្លូមខូចដែរនៅអាស្រ័យទៀតបាន ហេតុនោះបានជាយើងមិនឲ្យ យើងចាំជំរាបនាយសិនជាគាត់ឲ្យឬមិនឲ្យក៏តាមចិត្តលោកនាយចុះ"។

ឯនាយដង្កៅឮសត្វទាំងពីរដជែកគ្នាទៅនិញ្ជទៅមកដូច្នោះ ក៏ឆ្លើយកាត់ទៅវិងថា "ការអស់នេះជាទោសខុសធ្លាក់មកលើអញ្ជជានាយនិញ្ជចុះ ព្រោះអញ្ជមិនបានមើលកល មើលការផ្តាក់ផ្ទុកផ្តាំលាឲ្យបែងបាយថ្ងៃ ចែកឲ្យឆ្កែគ្នាស៊ីផង អើពីថ្ងៃនេះទៅលាឯងមើលពេលគួរឲ្យឆ្កែគ្នាបានអាស្រ័យផងចុះ"។ ថាហើយនាយដង្កៅក៏ទៀបប្រដាប់លើកដាក់លើតាងលាបនលាទៅកាន់ស្រុកនៃអាត្មាហោង។

ទើរឹងនេះ បានគតិដល់បុគ្គលអ្នកនៅនឹងនាយចៅហ្វាយឬគ្រូអាចារ្យ ដែលលោកឲ្យខ្លួនកឯ្រទ្រព្យសម្បត្តិ គួរយកគតិលាជាច្បាប់នៃអាត្មា ទើបបានក្តីគាប់ក្នុងលោកិយនេះហោង។

ចប់តម្រោគតិអ្នករក្សាទ្រព្យនាយទី ៣៣។

ទើរឹងដើងដែរប្រដែណនឹងមាត់

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានកាលថ្ងៃ១ ពួកអរិយទ:ទាំងឡាយគឺដែពីរ ដើងពីរ មាត់មួយនាំគ្នានិយាយថា "យើងសព្វថ្ងៃនេះលំបាកនឹងប្រកបការរកស៊ីណាស់"។ ដើងទាំងពីរឆ្លើយថា "ខ្ញុំឯងនេះព្រឹកទៀលកាលណាទរ៉ល់តែនឹងដើរទៅឯនោះខ្លះឯងនេះខ្លះមិនចេះឈប់ឈរទៀយ" ដែទាំងពីរឆ្លើយទៀងថា "ខ្ញុំឯងក៏ទរ៉ល់មិនមានឱកាសឈប់សោះទៀរតែដេកលក់ទើបបានឈប់ តែភ្លាក់ទៀងកាលណាទរ៉ល់តែចាប់នេះចាប់នោះ មិនចេះអស់ដោយហោចទៅតែត្រឹមស៊ីបាយស៊ីចំណីអ្វីៗ ដែក៏ទរ៉ល់បាប់ចំណីបញ្ចុកមាត់ដែរ"។ មាត់ឆ្លើយទៀងថា "ខ្ញុំឯងក៏ទរ៉ល់មិនឈប់ដូចគ្នា តែភ្លាក់ទៀងកាលណាចរចានិយាយថានេះ ថានោះទៅផ្សេងៗដោយហោចទៅតែត្រឹមបរិភោគអ្វីៗ មាត់ក៏ទរ៉ល់ទំពា ទរ៉ល់លេបអាហារបញ្ចូលទៅ ការភ្លាក់ជារឿងខ្ញុំឯងមានសភាពយ៉ាងនេះ"។ ដើងដែបានឮដូច្នោះ ក៏សួរទៅមាត់ថា "អាហារនោះតើធ្លាក់ទៅនៅលើរូបណា?"។ មាត់ប្រាប់ថា "អាហារអស់នោះតែស៊ីហើយ ក៏ធ្លាក់ទៅនៅលើក្រពះទាំងអស់"។ "អើសព្វអាហារដែលពួកយើងបាន

មកដោយដើរ ដោយចាប់កាន់ ដោយទំពាលេបចូលទៅ គឺទៅនៅលើក្រពះទាំងអស់ អាក្រពះនោះតើវាមកជួយធ្វើការអ្វីខ្លះដែរ ឬវានៅស្ងៀមព្រងើយកន្តើយទេ? មាត់ប្រាប់ថា "អាក្រពះនោះវានៅស្ងៀមទទេទេវានឹងបានជួយកិច្ចការអ្វីក៏ឥតអង្គុយមាន"។

ទើបជើងឆ្លើយទៅដៃថា "អញ្ញទៅលំដើរទៅរកស៊ីបានអាហារៗ នោះក៏គួរធ្លាក់មកលើអញ្ញអេះ នេះម្តេចទៅវិញក៏បានទៅលើអាក្រពះ ដែលវានៅស្ងៀមនោះវិញ បើដូច្នេះពីថ្ងៃនេះទៅ អញ្ញលែងដើរកស៊ីទៀតហើយ"។ ឯដៃក៏ពោលថា "អញ្ញខំធ្វើការសព្វសរពីសព្វថ្ងៃនេះ អាហារសោតក៏ធ្លាក់បានទៅលើអាក្រពះនោះវិញ បើដូច្នេះពីថ្ងៃនេះទៅ អញ្ញលែងចាប់ពាល់កាន់ធ្វើអ្វីៗហើយ ទុកឲ្យអាក្រពះវាចេញមកធ្វើការដាំស្ពដាក់ពោះវាចុះ"។ ឯមាត់ក៏ពោលទៀតថា "អញ្ញសោតខំនិយាយដេរពោលប្រទេច ខំស៊ី ខំទំពា ខំលេប ឯអាហារក៏ពុំតាំងនៅលើខ្លួនអញ្ញ វាត្រឡប់បានៅអាក្រពះនោះវិញ អាក្រពះវាគ្មានជួយធ្វើការអ្វីសោះ អើពីថ្ងៃនេះទៅអញ្ញលែងនិយាយលែងពោល លែងទំពាស៊ីអ្វីៗហើយ ទុកឲ្យអាក្រពះវា

ក្រៀមស្វិតពោះវាចុះទើបសមមុខវា ដែលវាកំដើលធ្វើការនេះ"។

ឯអវយវៈទាំង៣និយាយត្រូវគំនិតគ្នាហើយទើបចូលដេកលើគ្រែលែងប្រកបជាភ្នាក់ងារខ្លួនទៀតៗ ពីថ្ងៃនោះហោង។ ឯក្រពះនោះកាលអវយវៈក្រៅមិនបញ្ជូលអាហារទៅឲ្យដូច្នោះហើយ ក៏កើតស្ងួតក្រៀម ភ្លើងតេជោធាតុពុំមានអាហារនឹងដុតផ្សាយទៅសព្វសកលកាយបាន សកលកាយនោះកាលបើពុំមានរសអាហារនឹងផ្សាយហើយ វាយោធាតុក៏មានកំលាំងអាចផាត់អាបោធាតុ ឲ្យរីងស្ងួតស្វិតទៅខ្លះកាលបើធាតុប្រែប្រួលពុំប្រក្រតីហើយ ឯអវយវៈទាំងឡាយក៏ស្វិតស្គមរីងទៅ វាតសម្លាន់នាពាធក៏បៀតបៀតធ្វើឲ្យចុកសៀតទៅផ្សេងៗ។

ឯដៃជើងមាត់ទាំង៣ ពួកកាលណាបើកើតវិបត្តិដល់ខ្លួនទើបៗហើយ ពុំអាចនឹងតាំងនៅជាប្រក្រតីបាន ទើបមកប្រជុំគ្នាវិញទៀតថា ពួកយើងតាំងតែពីលើកលែងប្រកបការ មិនបញ្ជូលអាហារទៅឲ្យអាក្រពះនោះ ឥឡូវនេះវាស្វិតស្ងួតពុំបានផ្សាយរសជាតិអាហារដល់ពួកយើងទៀយ ពួកយើងបានក្តីស្តាំងស្គមទ្រុមទ្រុឌគ្មានកំលាំងសោះ មិនតែប៉ុណ្ណោះដាលកើតជា

នោតចុកសៀត នួយអស់សាច់សរទែសរថែមទៀត អើបើពួក
យើងបង្អត់អាហារ អាក្រពះយ៉ាងនេះហើយគង់នឹងអន្តរធាន
វិនាសទៅទាំងអស់គ្នាមិនខានព្រោះក្រពះគ្មានអាហារជាកំលាំ
ងនឹងផ្សាយរសជាតិដល់ពួកយើងនេះឯង បើដូច្នេះពួកយើង
ត្រូវទៅប្រកបការតាមភ្នាក់ងារទៀងខ្លួនដូចកាលមុនវិញ ពួកអវ
យវៈពិត្រោះឃើញក្តីទុក្ខទោសព្រមគ្នាដូច្នោះហើយ ដើងក៏
ក្រោកដើរទៅប្រកបការតាមដើម ដៃសោតដ៏ចាប់ពាលធ្វើ
ការងារតាមដើម មាត់សោតក៏ហានិយាយស្តី ហាស៊ីបានអាហារ
ដាក់ដូចមុនហើយ កើកមានកំលាំងផ្សព្វផ្សាយរសជាតិនោះ
ទៅសព្វសព៌ាង្គកាយ ដៃជើងមាត់ក៏បានក្តីសុខសប្បាយទៀង
ដូចប្រក្រតីតាមកាលមុននោះវិញហោង។

ទៀងនេះ បានគតិដល់បណ្តាអាណាប្រជាជនទាំងឡាយក្នុង
ប្រទេសរាជបុរី ទុកជាអវយវៈគឺដៃជើងមាត់ ឯក្រពះនោះ
ទុកជាមហាក្សត្រធិបតី មែនបើអាណាប្រជាជនទាំងឡាយ
មិនថ្វាយសួយសារអាករប្រាក់ពន្ធដារថ្លៃរាជការហើយ មហា
ក្សត្រាធិបតីនឹងដល់នូវក្តីក្រៃក្រ ពុំមានប្រាក់សម្រាប់ប្រកបការ
ទក្សព្រះនគរ នឹងចិញ្ចឹមក្រមការតាមក្រសួងទាំងឡាយមាន

ក្រុមយោធាទាហានជាដើម កាលបើស្តេចគ្មានក្រុមមន្ត្រីសេនា
បតីគ្រប់ក្រសួង ហើយនឹងផ្សាយអំណាចរក្សាអាណាប្រជាជន
ក្នុងប្រទេសខ្លួនទៅម្តេចបាន ពួកចោរ ពួកនាដបច្ចាមិត្រដឹងថា
ព្រះនគរពុំមានអំណាចហើយ ទាំងនឹងនាំគ្នាលើកមកបុកបែនប្តន់
ញាំញីចាប់មហាក្សត្រាយ៌ នឹងពួកអាណាប្រជានុរាស្ត្រយកជា
ឈ្លើយជាខ្ញុំគេអស់ទៅ បាននូវក្តីទុក្ខទៀនាព្រាត់ប្រាសចាកភូមិ
ចាកលំនៅទៅផ្សេងៗដូចគ្នានឹងក្រពះដែលពុំមានអាហារតាំង
នៅ នឹងផ្សាយរសជាតិទៅដល់អវយវៈតូចធំពុំបាននោះឯងពិត
មែនមហាក្សត្រាធិរាជពុំបាននកស៊ីជួយធ្វើការនារាស្ត្រ នៅតែក្នុង
ទាំងក្នុងដំណាក់ដូចគ្នា នឹងក្រពះពុំបានជួយធ្វើការពួកអវយវៈ
នោះឯង។ អ្នកមានបញ្ញាគួរពិចារណាមើលចុះ មហាក្សត្រាធិ
រាជនោះ ត្រូវតែអវយវៈខាងក្រៅគឺអាណាប្រជានុរាស្ត្រថ្វាយ
សួយសារអាករបងប្រាក់ថ្លៃពន្ធបំរុងឲ្យមហាក្សត្រាយ៌ លោក
នឹងបានចំណាយចែកចាយ សាងព្រះនគរឲ្យមាំមួន ខ្លួនរាស្ត្រនឹង
បានក្តីសុខឥតទុក្ខភ័យ ដែលកើតអំពីពួកពាលទាំងែហងនោះ
ហោង គួរបង់ប្រាក់ជូនរាជការហើយពួកយើងជារាស្ត្រទាសក្នុង
ព្រះនគរ កុំពោលថាមហាក្សត្រាយ៌នៅទំនេរទៀយ។

ចប់តម្រាគតិរាស្ត្របង់ប្រាក់ពន្ធទី ៣៤ (ចប់ ភាគទី ៦ តែប៉ុណ្ណោះ)។